


ឯកសារជំនួយស្មារតីសម្រាប់ពិភាក្សានៃ

# ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ




## ឯកសារជំនួយស្មារតីសម្រាប់ពិភាក្សានៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

រៀបរៀងឡើងដើម្បីជូនចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការចំណុះឱ្យក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និងក្រសួងស្ថាប័នពាក់ព័ន្ធ ជាមូលដ្ឋានចូលរួមចំណែកធ្វើការពិភាក្សាកែលំអតួនាទីនិងភារកិច្ចនៃក្រុមប្រឹក្សាដ៏មានសារសំខាន់នេះ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់របស់រាជរដ្ឋាភិបាល និងឱ្យសមស្របតាមស្ថានភាពជាក់ស្តែងនៅកម្ពុជា។

ខ្លឹមសារទាំងអស់នៃអត្ថបទគឺជាយោបល់ផ្ទាល់ខ្លួននិងជាការទទួលខុសត្រូវរបស់អ្នករៀបរៀងនេះ និងមិនឆ្លុះបញ្ចាំងចំពោះគោលជំហរទាំងមូលនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទទេ។

### រៀបរៀងដោយ

**ងី ចន្ទ្រ័ផល** ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ សំរាប់អណត្តិទី៤នៃរដ្ឋសភា (២០០៨-២០១៣) និងជាអនុប្រធានទី២នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ - ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ (២០០៦-២០០៨) ជាអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ (១៩៩៦-២០០៦) និងជាអ្នកសម្របសម្រួលគម្រោងអភិបាលកិច្ចល្អមូលដ្ឋានអភិវឌ្ឍន៍ជនបទចម្រុះ ដែលជាគំរោងឥណទានអន្តរជាតិ មានជាអាទិ៍ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ កម្មវិធីសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន (១៩៩៦-២០០៤)។ ឯកឧត្តមទទួលសញ្ញាប័ត្របរិញ្ញាវិទ្យាសាស្ត្រ (**BS**-១៩៨៤) និងសញ្ញាប័ត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងវិនិយោគ (**MBA**-១៩៨៦) នៃសាកលវិទ្យាល័យហាតហ្វ័ត-រដ្ឋខូណិចទីខិត-សហរដ្ឋអាមេរិក។

Email: MRDNGYCP@FORUM.ORG.KH

**ខែតុលា ឆ្នាំ២០០៨**

# មាតិកា


| ល.រ | ចំណងជើង | ទំព័រ |
|---|---|---|
| ១. | សេចក្តីផ្តើម | ៤ |
| ១.១ | លក្ខណៈទូទៅ | ៤ |
| ១.២ | កម្មវត្ថុនៃឯកសារ | ៦ |
| ២. | គោលនយោបាយនៃរាជរដ្ឋាភិបាលក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ | ៦ |
| ២.១ | ចតុកោណយុទ្ធសាស្ត្រទាំងបួនសំរាប់ជំរុញកំណើន | ៦ |
| ២.២ | ការអភិវឌ្ឍន៏វិស័យកសិកម្មនិងជនបទ | ៩ |
| ២.៣ | ការអភិវឌ្ឍន៏វិស័យឯកជន | ១១ |
| ២.៤ | សហគ្រាសខ្នាតតូច និងមធ្យម | ១២ |
| ២.៥ | ការអភិវឌ្ឍន៍ជនបទ | ១៤ |
| ២.៦ | វិស័យសន្តិសុខស្បៀង | ១៥ |
| ២.៧ | ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម | ១៦ |
| ២.៨ | ឱកាសផលិតស្បៀងនៃវិស័យកសិកម្ម | ១៧ |
| ២.៩ | ការកាត់បន្ថយភាពក្រីក្រពាក់កណ្តាលនាឆ្នាំ ២០១៥ | ១៨ |
| ៣. | តួនាទី និងយុទ្ធសាស្ត្រនៃក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍កសិកម្ម និងជនបទ | ១៩ |
| ៣.១ | ក្រសួងពាក់ព័ន្ធ | ១៩ |
| ៣.១.១ | ក្រសួងមហាផ្ទៃ | ១៩ |
| ៣.១.២ | ក្រសួងអភិវឌ្ឍន៍ជនបទ | ២០ |
| ៣.១.៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២១ |
| ៣.១.៤ | ក្រសួងធនធានទឹក និងឧតុនិយម | ២២ |
| ៣.១.៥ | ក្រសួងសុខាភិបាល | ២៣ |
| ៣.១.៦ | ក្រសួងបរិស្ថាន | ២៤ |
| ៣.១.៧ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ២៤ |
| ៣.២ | ស្ថាប័នពាក់ព័ន្ធ | ២៤ |
| ៣.២.១ | គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា | ២៤ |
| ៣.២.២ | ក្រុមប្រឹក្សាជាតិកំណែទំរង់រដ្ឋបាល | ២៥ |
| ៣.២.៣ | គណកម្មាធិការជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ២៦ |
| ៣.២.៤ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ២៦ |

| | | |
|---|---|---|
| ៤. | បញ្ហាប្រឈមមុខ និងអនុសាសន៍ | ២៦ |
| ៤.១ | បញ្ហាប្រឈម | ២៦ |
| ៤.២ | អនុសាសន៍ | ២៨ |
| ៥. | ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ២៩ |
| ៥.១ | ពង្រាងអនុក្រឹត្យ | ២៩ |
| ៥.២ | គោលគំនិតទូទៅ | ៣០ |
| ៥.៣ | សមាសភាព និងរចនាសម្ព័ន្ធ របស់ ក.ក.ជ | ៣០ |
| ៥.៤ | តួនាទី និងភារកិច្ចរបស់ ក.ក.ជ | ៣៣ |
| ៥.៥ | តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃ ក.ក.ជ | ៣៤ |
| ៥.៦ | តួនាទី និងភារកិច្ចរបស់នាយកដ្ឋាន | ៣៥ |
| ៥.៦.១ | នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | ៣៥ |
| ៥.៦.២ | នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ | ៣៦ |
| ៥.៦.៣ | នាយកដ្ឋាន សុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៣៦ |
| ៥.៦.៤ | នាយកដ្ឋាន កសិកម្ម និងបរិស្ថាន | ៣៦ |
| ៥.៦.៥ | នាយកដ្ឋាន អភិវឌ្ឍន៍ជនបទ | ៣៧ |
| ៥.៦.៦ | នាយកដ្ឋាន ធនធានទឹក | ៣៨ |
| ៥.៦.៧ | នាយកដ្ឋានសាធារណៈការ | ៣៨ |
| ៥.៧ | សកម្មភាពជាបន្ត | ៣៩ |
| ៦. | ការវិភាគទៅលើអភិក្រមនៃដំណើរការអគ្គលេខាធិការដ្ឋាននៃ ក.ក.ជ | ៣៩ |
| ៦.១ | តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការទ្រទ្រង់នយោបាយ | ៤០ |
| ៦.២ | តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធនិងភាពជាដៃគូ | ៤១ |
| ៦.៣ | តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការគ្រប់គ្រងពត៌មាន និងចំណេះដឹង | ៤២ |
| ៦.៤ | តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ | ៤២ |
| ៧ | ការវាយតម្លៃលើបញ្ហាប្រឈម និងនិតិវិធីនៃដំណើរការសកម្មភាពខ្សែទទឹង | ៤៣ |

## ១. សេចក្តីផ្តើម

### ១.១ លក្ខណៈទូទៅ

**១.** ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិឆ្នាំ ២០០៦-២០១០ សម្រាប់រយៈពេលប្រាំឆ្នាំរបស់រាជរដ្ឋាភិបាល ទទួលស្គាល់ថា អាទិភាពខ្ពស់ជាងគេមួយ គឺត្រូវគិតគូរអំពីការអភិវឌ្ឍន៍ជនបទ និងធ្វើឱ្យជីវភាព និងរបរចិញ្ចឹមជីវិតទាំងឡាយនៅតាមជនបទក្រីក្រ បានប្រសើរឡើង។ ដោយអនុលោមតាមផែនការអភិវឌ្ឍជាយុទ្ធសាស្ត្រជាតិនេះ ការកែលំអជីវភាព និងរបរចិញ្ចឹមជីវិតនៅតាមជនបទក្រីក្រ គួរតែជាអាទិភាពខ្ពស់ជាងគេមួយរបស់រដ្ឋាភិបាល និងថាការពន្លឿនការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា គឺមួយផ្នែកធំ ត្រូវធ្វើយ៉ាងណាជួយបង្កើនផលិតភាព និងបង្កើនប្រាក់ចំណូលពីវិស័យកសិកម្ម។ គេត្រូវបំពេញលើក្បាលម៉ាស៊ីននានានៃកំណើនសេដ្ឋកិច្ច ដែលកំពុងតែមានការរីកចម្រើនតាំងពីដើមទសវត្សឆ្នាំ ១៩៩០ មក ដោយបន្ថែមលើប្រភពផ្សេងទៀត ដែលទាក់ទងនឹងការអភិវឌ្ឍជនបទឱ្យបានច្រើនជាងមុន មានមូលដ្ឋានធំទូលាយជាងមុន និងគិតគូដល់ប្រជាជនក្រីក្រជាងមុន។

**២.** ក្នុងឆ្នាំ២០០៨ ពិសេសនៅអំឡុងខែកញ្ញា និងតុលា ឆ្នាំ២០០៨ នេះ យើងទាំងអស់គ្នាបានឃើញនិងតាមដាន ដោយយកចិត្តទុកដាក់លើបាតុភាពមួយចំនួន ដែលបាននិងកំពុងកើតឡើងលើពិភពលោក ជាអាទិ៍បញ្ហាឡើងថ្លៃស្បៀង និងប្រេងឥន្ធនៈ បញ្ហាធាតុអាកាស ការឡើងកំដៅលើផែនដី ជាពិសេសវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅសហរដ្ឋអាមេរិក ដែលកំពុងជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ ដល់ប្រទេសអភិវឌ្ឍន៍និងកំពុងអភិវឌ្ឍន៍។ តើប្រទេសកម្ពុជា អាចគេចផុតពីវិបត្តិទាំងនោះឬទេ? តាមរយៈការវិភាគរបស់អ្នកសេដ្ឋកិច្ចនិងអ្នកប្រតិបត្តិធនាគារនៅប្រទេសកម្ពុជា[១] ការប្រឈមនឹងវិបត្តិហិរញ្ញវត្ថុនៅលើពិភពលោកបច្ចុប្បន្ន ដែលរាលដាលពីសហរដ្ឋអាមេរិក មកអឺរ៉ុប និងដល់ប្រទេសនានាក្នុងតំបន់មិនធ្វើឱ្យប៉ះពាល់ដល់វិស័យធនាគារ និងទីផ្សារហិរញ្ញវត្ថុនៅក្នុងប្រទេសឡើយ ផ្ទុយទៅវិញវិបត្តិនេះអាចនាំមកនូវភាពវិជ្ជមានមួយចំនួនដល់ប្រទេសកម្ពុជាទៅវិញទេ ព្រោះ **"ធនាគារនៅក្នុងស្រុកខ្មែរគ្មានវិនិយោគនៅទីផ្សារខាងក្រៅ"**។ ប៉ុន្តែផលដែលអាចប៉ះពាល់ ជាអវិជ្ជមានពីវិបត្តិនោះគឺអាចបង្អាក់ដំណើរអ្នកវិនិយោគទុនបរទេសដែលចង់មកវិនិយោគនៅកម្ពុជា ឬក៏អាចធ្វើឱ្យកម្មវិធីជំនួយមួយចំនួនមានការយឺតយ៉ាវ ។

**៣.** រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់បញ្ចៀសនិងកាត់បន្ថយនៅគ្រប់ហានិយភ័យទាំងឡាយណាដែលអាចកើតមានឡើងជាយថាហេតុ។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ រាជរដ្ឋាភិបាល នឹងបន្តពុះពារដើម្បីសម្រេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុង១ឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ។ ក្នុងចំណោមវិធានការចាំបាច់មួយចំនួនដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនឹងបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និងបណ្តាញចែកចាយថាមពល ដែលអាចកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ច និងលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងបង្កើនការវិនិយោគសំរាប់បង្កើនផលិតភាពកសិកម្មក្នុងគោលដៅឆក់ឱកាសនៃការកើនឡើងនូវសេចក្តីត្រូវការស្បៀងនៅក្នុងពិភពលោក ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា។

---

[១] ដកស្រង់ពីកាសែត **រស្មីកម្ពុជា** ឆ្នាំទី១៦ លេខ៤៧១៩ ថ្ងៃសៅរ៍ទី១៨ ខែតុលា ឆ្នាំ២០០៨ " **អ្នកសេដ្ឋកិច្ចៈ ធនាគារនៅកម្ពុជាមានស្ថិរភាពទោះបីពិភពលោកនិងតំបន់ កំពុងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុ**" ដោយ ពិស្ចារ

៤. នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជា សំរាប់នីតិកាលទី៤ នៃរដ្ឋសភា បានបើកកិច្ចប្រជុំពេញអង្គរបស់ខ្លួនលើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដោយមានការចូលរួមពីគ្រប់សមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល ដើម្បីប្រកាសជូនជនរួមជាតិកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់ឱ្យបានជ្រាបអំពីអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលថ្មី និងអំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតឥតងាករេរបស់រាជរដ្ឋាភិបាលទាំងមូល ក្នុងការបន្តអនុវត្តកម្មវិធីកំណែទម្រង់តាមមុខព្រួញសំខាន់ៗ ក្នុងគោលដៅបំរើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ និងឆ្លើយតបទៅនឹងសំណូមពរ និងសេចក្តីត្រូវការទាំងឡាយរបស់ប្រជាជនកម្ពុជា។ នៅក្នុងខ្លឹមសារដើមនៃសេចក្តីថ្លែងការនយោបាយនោះ **សម្តេចអគ្គមហាសេនាបតីតេជោ** បានជម្រាបជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីទាំងមូលពីការកំណត់ជាយុទ្ធសាស្ត្រថា **កំណែទម្រង់គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា**។ ក្នុងន័យនេះ កម្ពុជាគ្មានជម្រើសអ្វីផ្សេងក្រៅពីការបន្តជម្រុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និងហ្មត់ចត់បំផុតនូវកំណែទម្រង់ទាំងឡាយដែលបានដាក់ចេញកន្លងមកនេះ ឱ្យបានកាន់តែទូលំទូលាយនិងស៊ីជម្រៅថែមទៀត ដែលជាលក្ខខណ្ឌចាំបាច់បំផុតសំរាប់ធានាបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ទស្សនទាននេះ កំពុងតែឆ្លុះបញ្ចាំងនូវភាពត្រឹមត្រូវ និងភាពពេញលេញរបស់ខ្លួនក្នុងសភាពការណ៍ពិភពលោក និងសភាពការណ៍កម្ពុជាបច្ចុប្បន្ន។

៥. នៅក្នុងសារលិខិតសម្រាប់ការតាក់តែងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ទទួលស្គាល់ពីភាពចាំបាច់ចម្បងៗ ក្នុងការបង្កើត និងពង្រឹងស្ថាប័នអភិបាលកិច្ច ដំណើរការ និងនិតិវិធីឱ្យបានប្រសើរជាងមុន តាមរយៈកំណែទម្រង់ដែលមានផែនការច្បាស់លាស់ សំដៅធានាបានការអភិវឌ្ឍប្រកបដោយចិរភាព។ ទោះជាយ៉ាងណា ការងារនេះមិនអាចកសាងឡើងក្នុងរយៈពេលតែមួយថ្ងៃអោយហើយនោះទេ ចំណែកឯស្ថាប័នរបស់ប្រទេសកម្ពុជាទាំងមូល ដែលត្រូវបានបំផ្លិចបំផ្លាញដល់ឫសគល់ក៏មិនអាចកសាងឡើងវិញ តែក្នុងរយៈពេលមួយយប់នោះដែរ ក្នុងនោះរួមមានការកសាងស្ថាប័នសេដ្ឋកិច្ច សង្គមកិច្ច រដ្ឋាភិបាល ហិរញ្ញវត្ថុ និងស្ថាប័នផ្សេងៗទៀត។ ប៉ុន្តែជាជំហានៗ វឌ្ឍនភាពបានកើតមានជាបន្តបន្ទាប់ ហើយបានចាប់ផ្តើមក្នុងជំហានដ៏ឆាប់រហ័ស ដែលមិនធ្លាប់មាននៅកន្លែងផ្សេងទៀតនៃពិភពលោក។

៦. នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ទ្រង់បានឡាយព្រះហស្តលេខាត្រាស់បង្គាប់ តែងតាំងសមាសភាពថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទថ្មីបន្ថែម[២] ដែលមាន **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ជាប្រធាន និងមានអនុប្រធាន ៣រូប អគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង ១១រូប។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨នៅក្នុងសម័យប្រជុំប្រកាសសមាសភាពថ្នាក់ដឹកនាំថ្មី **ឯកឧត្តម យឹម ឆៃលី** បានលើកឡើងអំពីអាទិភាពគោលនយោបាយសំខាន់ៗ ជាពិសេសការអនុវត្តបន្តនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលសំរាប់នីតិកាលថ្មី និងអំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតឥតងាករេរបស់រាជរដ្ឋាភិបាល។ **ឯកឧត្តម** ក៏បានរំលឹកអំពីតួនាទីនិងភារកិច្ច ដែលឥតខ្ចោះបានរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្នុងការសម្របសម្រួលសិក្សា តាមដានវាយតម្លៃ ដកបទពិសោធន៍ នៃមុំចតុកោណវិស័យអភិវឌ្ឍន៍កសិកម្ម ដែលជាគោលនយោបាយរបស់រាជដ្ឋាភិបាល

[២] ព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១៣៨ ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០០៨

សំដៅជាសំខាន់ទៅលើការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធភាវូបនីយកម្មវិស័យកសិកម្ម ក្នុងការពង្រឹងនិងពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចជាតិ ដែលអាចផ្តល់ឥទ្ធិពលជាវិជ្ជមានយ៉ាងឆាប់រហ័ស ទៅលើកិច្ចការខិតខំប្រឹងប្រែងរបស់យើង ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាជនតាមទីជនបទទៀតផង។ ការងារនេះតម្រូវឱ្យមានយន្តការស្ថាប័ន និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យមានវឌ្ឍនភាព និងការប្រែប្រួលជាគុណភាពក្នុងវិស័យទាំងមូល។

### ១.២ គម្រូវត្ថុនៃឯកសារ

**៧.** ឯកសារនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបង្កើតនូវមូលដ្ឋានបឋម សម្រាប់ការយល់ដឹងលើការអភិវឌ្ឍន៍កសិកម្មនិងជនបទនៅប្រទេសកម្ពុជា ពិសេសដើម្បីរំលេចពីសារៈសំខាន់នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទក្នុងការសម្របសម្រួលវិស័យនេះអោយប្រព្រឹត្តទៅបានរលូន។ ក្នុងនោះ បរិយាកាសទូទៅមួយចំនួនដែលនៅហ៊ុំមព័ទ្ធនិងគ្របដណ្តប់លើការអភិវឌ្ឍន៍កសិកម្មនិងជនបទ និងភាពរហ័សរហួននៃរាជរដ្ឋាភិបាល ក្នុងការតាក់តែងនិងរៀបចំគោលនយោបាយសម្រាប់វិស័យនេះ នឹងត្រូវបានលើកយកមកបង្ហាញ។ ឯកសារនេះនឹងធ្វើការបង្ហាញនូវតួនាទីនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអភិវឌ្ឍន៍ដែលពាក់ព័ន្ធក្នុងសកម្មភាពអនុវត្តគោលនយោបាយនេះ។ លទ្ធភាពនៃភាពជាដៃគូ និងការប្រាស្រ័យទាក់ទងរវាងស្ថាប័នទាំងនេះ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលជាអន្តរការីនឹងត្រូវបានលើកឡើង។

**៨.** អាស្រ័យហេតុនេះដោយឈរលើមូលដ្ឋាននៃការអនុវត្តគោលនយោបាយនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនីតិកាលទី៤ និងដើម្បីរិះរកវិធីសាស្ត្រសមស្រប និងពិនិត្យវាយតម្លៃកែលម្អរចនាសម្ព័ន្ធដឹកនាំការងារ ឱ្យរឹតតែមានប្រសិទ្ធភាពថែមទៀត ឯកសារជំនួយស្មារតីនេះ គឺជាការសាកល្បងចងក្រងប្រមូលផ្តុំខ្លឹមសារសង្ខេបជាគន្លឹះនៃយុទ្ធសាស្ត្រចតុកោណនិងយុទ្ធសាស្ត្រតាមវិស័យសំខាន់ៗ និងតួនាទីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលមានតួនាទីជាគណៈបញ្ជាការឯកភាពមួយជំនួយការឱ្យរាជរដ្ឋាភិបាលក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលជាជ្រុងអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទាំងមូល។

## ២. គោលនយោបាយនៃរាជរដ្ឋាភិបាលក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទ

### ២.១ ចតុកោណយុទ្ធសាស្ត្រនាំចប្អូនសម្រាប់ជម្រុញកំណើន

**៩.** រាជរដ្ឋាភិបាលបានយក **កម្មវិធីនយោបាយ** សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ដែលត្រូវបានតាក់តែងឡើង និងអនុម័តដោយផ្អែកលើការវាយតម្លៃលទ្ធផលការងារ ដែលបានអនុវត្តក្នុងនីតិកាលទី៣ និងដោយផ្អែកលើឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងផ្អែកលើបរិការណ៍ជាតិ និងអន្តរជាតិ មកធ្វើអាទិភាវូបនីយកម្ម នូវបណ្តាអាទិភាពដែលត្រូវបានដាក់ចេញមក ហើយរៀបចំលំអិតសម្រិតសម្រាំងសម្រួចបន្ថែម សំដៅរំលេចឱ្យចេញរបៀបវារៈនយោបាយសង្គម-សេដ្ឋកិច្ច របស់កម្មវិធីនយោបាយនេះ និងឱ្យចេញជាកញ្ចប់អាទិភាពនៅតាមវិស័យសំខាន់ៗនានា ដែលមានលក្ខណៈជាប្រព័ន្ធស៊ីសង្វាក់ ប្រទាក់ក្រឡានិងយោងគ្នាទៅវិញទៅមក សម្រាប់ជាមូលដ្ឋាននាំទៅសម្រេចឱ្យបាននូវចក្ខុវិស័យរួមរបស់ជាតិ។ របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចនេះ គឺជាសេចក្តីប្រកាសអំពីបេសកកម្ម និងការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្នុងសកម្មភាពកែ

ទម្រង់ ដើម្បីពង្រឹងគុណភាពអភិបាលកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ ដែលជាកត្តាដ៏ចាំបាច់បំផុត សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ [៣] ។

**១០.** ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺ **អភិបាលកិច្ចល្អ** គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយសម្រាប់ធានាឱ្យមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាពសមធម៌និងយុត្តិធម៌ក្នុងសង្គម។ នៅក្នុងនីតិកាលទី៤នៃរដ្ឋសភានេះ កំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល នឹងផ្តោតជាសំខាន់ទៅលើការបង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយ និងក្នុងការផ្តល់ និងការគ្រប់គ្រងសេវាសាធារណៈ ជាពិសេសការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន។ ក្នុងការរក្សាឱ្យបាននូវបរិស្ថានគ្របដណ្តប់សំរាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល រាជរដ្ឋាភិបាលនឹងបន្តការងាររបស់ខ្លួនក្នុងគោលដៅពង្រឹងថែមទៀតនូវសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជូនដល់ប្រជាជន ដើម្បីធានាពង្រឹងលក្ខខណ្ឌគ្រឹះនៃការកសាង និងកែទម្រង់រដ្ឋ សំរាប់ការបោះជំហានរបស់កម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍ និងភាពកាន់តែចម្រើនរុងរឿង។

**១១.** ដំណើរការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងតំបន់ និងពិភពលោក និងការអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ បានបង្កើនបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ទេសចរណ៍ និង ឧស្សាហកម្ម ជាពិសេសឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងបានបង្កលក្ខណៈសម្បត្តិ ឱ្យកសិករកម្ពុជាអាចលក់ដូរផលិតផលរបស់ខ្លួននៅលើទីផ្សារតំបន់និងអន្តរជាតិ។ រាជរដ្ឋាភិបាលនីតិកាលទី៤ នឹងផ្តល់អាទិភាពលើការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ។ រាជរដ្ឋាភិបាល បានសម្រេចលទ្ធផលជាច្រើនក្នុងការពង្រឹងភាពជាដៃគូ ជាមួយតួអង្គអនុវត្តទាំងអស់ ដែលក្នុងនោះរួមមានសហគមន៍ ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិលដោយឈរលើគោលការណ៍ជាមូលដ្ឋាន និងការប្តេជ្ញាដែលមានចរិតសាកលនានា ដែលធានាឱ្យមានភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំកិច្ចអភិវឌ្ឍប្រទេសជាតិ។ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងយន្តការសំរាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ក៏ដូចជាបណ្តាភាគីពាក់ព័ន្ធទាំងឡាយចូលរួមពិភាក្សារាល់បញ្ហានានា ទាំងវិស័យសាធារណៈ និងវិស័យឯកជន។ រាជរដ្ឋាភិបាល បន្តលើកទឹកចិត្ត អង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ ឱ្យចូលរួមក្នុងកិច្ចដំណើរការស្តារនិងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងលើកស្ទួយការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការតាមដាន ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានាផងដែរ។ បរិស្ថានទី៤ សំរាប់គ្របដណ្តប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ គឺបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ។ រាជរដ្ឋាភិបាល នឹងបន្តពុះពារដើម្បីសំរេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុង ១ឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ។ ក្នុងចំណោមវិធានការចាំបាច់មួយចំនួនដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលនឹងបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ

---

[3] សុន្ទរកថា របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី **យុទ្ធសាស្ត្រចតុកោណ** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ដំណាក់កាលទី២ ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ។

និងបណ្ដាញចែកចាយថាមពល ដែលអាចកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ច និងលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងបង្កើនការវិនិយោគសំរាប់បង្កើនផលិតភាពកសិកម្ម ក្នុងគោលដៅឆក់យកឱកាសនៃការកើនឡើងនូវសេចក្ដីត្រូវការស្បៀងនៅក្នុងពិភពលោក ដើម្បីជម្រុញការអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា។ រាជរដ្ឋាភិបាល ប្ដេជ្ញាគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនូវចំណូល ដែលបានមកពីការធ្វើអាជីវកម្មលើ ធនធាន រ៉ែ ប្រេងកាត និងឧស្ម័ន។

**១២.** ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បណ្ដាញគមនាគមន៍ មានតួនាទីជា ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច និងជាសរសៃឈាមសំរាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជណាចក្រកម្ពុជា ឱ្យក្លាយជាសរីរាង្គសេដ្ឋកិច្ចមួយ ក្នុងគោលដៅធ្វើសមាហរណកម្មផ្ទៃក្នុងខ្លួនឯងផង និងក្នុងគោលដៅសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោកផង ។ រាជរដ្ឋាភិបាល នឹងបន្តផ្ដល់អាទិភាពខ្ពស់ទៅលើការស្ដារ និងកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពហុប្រភេទ ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស និងតភ្ជាប់ជាមួយបណ្ដាប្រទេសជិតខាងឱ្យទៅជាប្រព័ន្ធគមនាគមន៍ និងបណ្ដាញសេវាដឹកជញ្ជូនមួយងាយស្រួល មានស្ថិរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាប ក្នុងទិសដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជម្រុញវិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងសកលលោក ព្រមទាំងបម្រើដល់កិច្ចការពារជាតិថែមទៀត។ រាជរដ្ឋាភិបាលនឹងបន្តផ្ដល់អាទិភាពខ្ពស់ដល់ការស្ដារ ការកសាង ការថែទាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អាងស្ដុកទឹក ប្រឡាយទឹក លូទឹក ប្រព័ន្ធដោះទឹក ប្រឡាយនាំដីល្បាប់ ទំនប់ ការពារទឹកជំនន់-ទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនផ្ទៃដីស្រោចស្រព និងជំរុញការងារបង្កបង្កើនផល ។ រាជរដ្ឋាភិបាល នឹងបន្តផ្ដោតការយកចិត្តទុកដាក់លើការធានាសិទ្ធិរបស់ប្រជាពលរដ្ឋ តាមរយៈការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាជនគ្រប់រូប ដើម្បីធានាសន្តិសុខស្បៀង ក្នុងជីវភាពរស់នៅរបស់ប្រជាជន ស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងតាមរយៈការធានាបាននូវប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានគ្មានការបំពុល។

**១៣.** ក្នុងការលើកកម្ពស់សេវាសុខាភិបាល រាជរដ្ឋាភិបាលបានចាត់ទុកថា សុខភាពប្រជាពលរដ្ឋ គឺជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍន៍ធនធានមនុស្ស វឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។ រាជរដ្ឋាភិបាល បានលើកស្ទួយសុខមាលភាពប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ។ ក្នុងនីតិកាលទី៤ នេះរាជរដ្ឋាភិបាល បន្តជម្រុញអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលក្នុងគោលដៅកាត់បន្ថយអត្រាស្លាប់របស់មាតា និងទារក និងកែលំអសូចនាករសុខាភិបាលសំខាន់ៗផ្សេងទៀតតាមរយៈការពង្រឹងគុណភាព និងពង្រឹងសេវាសុខាភិបាល ជាពិសេសសេវាសុខភាពបន្តពូជ មាតា ទារក និងកុមារ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តវិធានការចាំបាច់នានា ដើម្បីធ្វើឱ្យសេវាសុខាភិបាលកាន់តែឆ្លើយតបនិងខិតកាន់តែជិតសាធារណៈជន តាមរយៈការអនុវត្តវិមជ្ឈការលើមុខងារផ្ដល់សេវា និងការធ្វើវិមជ្ឈការការគ្រប់គ្រងទៅថ្នាក់ក្រោមជាតិ ដូចជា មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ការបង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បរិក្ខារពេទ្យ និងបច្ចេកវិទ្យា ជាមួយនិងការលើកកម្ពស់ការស្រាវជ្រាវសុខភាព សម្រាប់ការកសាងគោលនយោបាយ ផែនការ ការពិនិត្យ តាមដានសមិទ្ធផល និងការវាយតម្លៃការពង្រឹងអភិបាលកិច្ចទូទាំងវិស័យសុខាភិបាលតាមរយៈការអនុវត្ត **"អភិក្រមគ្របដណ្ដប់ទូទាំងវិស័យ"** ដោយត្រូវបង្កើនភាពជាម្ចាស់ និងពង្រឹងភាពជាដៃគូជាមួយសហគមន៍អន្តរជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀតក្នុងវិស័យសុខាភិបាល និងពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ។

**១៤.** ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល ខិតខំពុះពារអោយអស់ពីសមត្ថភាព ដើម្បីសម្រេចបាននូវគោលដៅជាអាទិភាព ក្នុងនីតិកាលទី ៤ នេះ គឺ **ទី១.** ការធានាអោយបាននូវចីរភាពសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម សំដៅលើការលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធប្រជាធិបតេយ្យសេរីពហុបក្ស។ **ទី២.** ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាពក្នុងក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ ទៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុននៅក្នុងបរិយាកាស អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់។ **ទី៣.** ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយនៃភាពក្រីក្រឱ្យបានលើស១% ក្នុងមួយឆ្នាំ និងការធានាការកែលំអសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេសវិស័យអបរំ សុខាភិបាល និងសមភាពយេនឌ័រ។ **ទី៤.** ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្ត។

## ២.២ ការអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

**១៥.** គេគួរធ្វើការចាប់អារម្មណ៍បន្ថែមថា ក្នុងបរិការណ៍នៃគោលនយោបាយសេដ្ឋកិច្ច រាជរដ្ឋាភិបាលនឹងបន្តជម្រុញការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដោយផ្តោតអាទិភាពទៅលើវិស័យចំនួន ១០ ដែលក្នុងនោះ កសិកម្មជាអាទិភាពមួយ។ រាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍន៍វិស័យកសិកម្មអោយមានការរីកចម្រើន និងក្លាយជាវិស័យនាំមុខមួយពិតប្រាកដនៃសេដ្ឋកិច្ចជាតិ ធ្វើជាប្រភពកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ពង្រីកមូលដ្ឋាននៃសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ តួនាទីនៃការអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សម្រាប់ពន្លឿនកំណើននៃវិស័យសេដ្ឋកិច្ច ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលទី ៤ នៃរដ្ឋសភា ពិសេសនៅក្នុងគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាពនៅកម្ពុជា។

**១៦.** នៅកម្ពុជា កសិកម្មនៅតែជាប្រភពកំណើនដ៏សំខាន់មួយដែលមានចំនួនប្រមាណ ៣០ភាគរយ នៃកំណើនផលិតផលក្នុងស្រុកជាមធ្យមនិងជាយន្តការ មួយសំរាប់ការកាត់បន្ថយភាពក្រីក្រដែលភាគច្រើននៃប្រជាពលរដ្ឋក្រីក្រ រស់នៅតំបន់ជនបទ (៧៨%)។ ក្នុងទិសដៅនេះ ការលើកកំពស់វិស័យកសិកម្មនឹងផ្តល់នូវផលប្រយោជន៍ពីរយ៉ាង គឺ ទី១ បង្កើនជីវភាពរស់នៅរបស់ប្រជាជននៅជនបទផង និងទី២ គឺការបង្កើតមូលដ្ឋានសំរាប់ការកសាងរោងចក្រ កែច្នៃកសិផល និងសំរាប់ការនាំចេញផង។

**១៧.** ការលើកស្ទួយវិស័យកសិកម្ម និង ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាជ្រុងនៃចតុកោណទី១ និងទី២ នៃយុទ្ធសាស្ត្រចតុកោណ ដែលនឹងបន្តអនុវត្តនៅក្នុងដំណាក់កាលទី២ នៃរាជរដ្ឋាភិបាលអណត្តិទី៤ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ដោយសារកំណើនសេដ្ឋកិច្ចនៅកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ហើយវិស័យកសិកម្ម នៅតែជាវិស័យដែលស្រូបពលកម្មច្រើនជាងគេ គួបផ្សំនឹងការកើនឡើងថ្លៃស្បៀងអាហារនៅលើពិភពលោក ការអភិវឌ្ឍវិស័យកសិកម្ម ដែលជាស្នូលនៃសេដ្ឋកិច្ចជនបទ មានអត្ថន័យពីរយ៉ាងគឺការពង្រីកមូលដ្ឋាន និងការជួយរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ចផង និងពន្លឿនការកាត់បន្ថយភាពក្រីក្រផង។ ក្នុងគោលដៅនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាលសំដៅជាសំខាន់ទៅលើការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធភាវូបនីយកម្មវិស័យកសិកម្ម ព្រមទាំងលើកំណែទំរង់ដីធ្លី កំណែទំរង់ជលផល និងកំណែទំរង់ ព្រៃ ឈើ ដោយដោះស្រាយជាកញ្ចប់ នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវថ្នល់ ធារាសាស្ត្រ និង អគ្គិសនី

ព្រមទាំងឥណទានទីផ្សារ និងការកែឆ្នៃកសិផល ជាពិសេសការកែឆ្នៃសំរាប់នាំចេញ ។ ការងារនេះតំរូវឱ្យមានយន្តការ ស្ថាប័ន និងការសំរបសំរួល ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យមានវឌ្ឍនភាព និងការប្រែប្រួលជាគុណភាព ក្នុងវិស័យទាំងមូល ។

**១៨. សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលបានមានប្រសាសន៍ ក្នុងឱកាសធ្វើបទឧទ្ទេសនាមលើប្រធានបទ **"រដ្ឋាភិបាលសេដ្ឋកិច្ច និងយុទ្ធសាស្ត្រលើកកំពស់ជីភាពនៅជនបទ"** ថ្ងៃទី១២ ខែឧសភា ឆ្នាំ ២០០៣ ដើម្បីចូលរួមចំណែកក្នុងការសំរេចគោលដៅនៃការអភិវឌ្ឍន៍សហស្សវត្សរ៍និងដើម្បីឱ្យសមស្របទៅនិងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកំពស់ជីវភាពប្រជាជននៅជនបទ ឱ្យកាន់តែប្រសើរឡើង និងដើម្បីសំរេចបាននូវនិរន្តរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅជនបទ ជាមួយនិងការធានាថាផលប្រយោជន៍នៃការអភិវឌ្ឍន៍កសិកម្មនិងជនបទ នឹងត្រូវបែងចែកដោយសមស្របទៅគ្រប់គ្រួសារនៅជនបទនោះ យើងត្រូវបន្តកែលំអគោលនយោបាយអភិវឌ្ឍន៍ជនបទរបស់យើង ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការងារជាយុទ្ធសាស្ត្រចំនួនបី[4] ។

**១៩. ទីមួយ- ការអនុវត្តន៍នូវកម្មវិធីវិមជ្ឈការ** ដោយធានាឱ្យបាននូវការពង្រឹងសមត្ថភាពនៅគ្រប់ថ្នាក់ទាំងអស់ ដើម្បីឱ្យពួកគេបំពេញភារកិច្ចបានត្រឹមត្រូវ ផ្តល់សេវាប្រកបដោយប្រសិទ្ធិភាព ព្រមទាំងមានសមត្ថភាព ក្នុងការពិនិត្យនិងតាមដានសកម្មភាព នានាដើម្បីរក្សាគុណភាពសេវា និងលើកកំពស់ការអនុវត្តន៍អភិបាលកិច្ចល្អ។ ការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តនានា ដូចជាការកសាង ផែនការអភិវឌ្ឍន៍ ការកៀងគរធនធាន ការកំណត់អាទិភាពសកម្មភាពការអនុវត្តន៍ សកម្មភាពនិងការផ្តល់សេវាដោយស្មើភាព ។ល។ នឹងធ្វើឱ្យវិមជ្ឈការអាចចូលរួមចំណែកបានយ៉ាងពេញទំហឹង និងប្រកបដោយប្រសិទ្ធិភាពក្នុងការដោះស្រាយភាពក្រីក្ររបស់ប្រជាជន។ និយាយជារួម ពលរដ្ឋគឺជាតួអង្គស្នូលនៅក្នុងយន្តការនានានៃដំណើរការវិមជ្ឈការ។ ដូច្នេះ ការអភិវឌ្ឍន៍ធនធានមនុស្ស ការផ្លាស់ប្តូរឥរិយាបទនិងទំលាប់របស់ប្រជាជននៅក្នុងមូលដ្ឋានគឺជាគន្លឹះ ដ៏សំខាន់មួយ នៅក្នុងការខិតខំដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីជំរុញការរីកលូតលាស់នៃលទ្ធិភាពប្រជាធិបតេយ្យ។

**២០. ទីពីរ-ការបន្តជំរុញវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅជនបទ** ឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀតរាជរដ្ឋាភិបាល បាន និងកំពុងតែជួសជុល និងសាងសង់ថ្មីថែមទៀតនូវផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំនិងស្ពាន ព្រមទាំងប្រព័ន្ធធារាសាស្ត្រ តូចធំចំនួនរាប់ពាន់គីឡូម៉ែត្រ ដើម្បីអូសទាញកំណើនសេដ្ឋកិច្ចនិងដោះស្រាយសម្រួលដល់ជីវភាពរបស់ប្រជាជន ជាពិសេសគឺប្រជាជននៅជនបទ។ និយាយឱ្យខ្លីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅជនបទ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សំរាប់បំរើឱ្យមធ្យោបាយទាំងបីយ៉ាងនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រគឺ : ទី១ -ការបង្កើតនូវកាលានុវត្តភាព ទី២- ការធានានូវសន្តិសុខ និងសុវត្ថិភាព និងទី៣-ការពង្រឹង ពង្រីកសមត្ថភាព និងការផ្តល់អំណាច។ រាជរដ្ឋាភិបាលអណត្តិទី៣ គឺជារាជរដ្ឋាភិបាលធារាសាស្ត្រ។

**២១. ទីបី- ការអភិវឌ្ឍន៍វិស័យកសិកម្ម** រាជរដ្ឋាភិបាលយើងសំរេចបាននូវជោគជ័យគួរឱ្យលើកទឹកចិត្តក្នុងការជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច។ ប៉ុន្តែកំណើននេះនៅមានមូលដ្ឋានតូចចង្អៀត ដោយសារវាពឹងផ្អែកជាសំខាន់ទៅលើវិស័យតែពីរប៉ុណ្ណោះ

---

[4] ***សម្តេច ហ៊ុន សែន*** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលបានមានប្រសាសន៍ ក្នុងឱកាសធ្វើ បទឧទ្ទេសនាមលើប្រធាន បទ ***"រដ្ឋាភិបាលសេដ្ឋកិច្ច និងយុទ្ធសាស្ត្រលើកកំពស់ជីភាពនៅជនបទ"*** ថ្ងៃទី១២ ខែឧសភាឆ្នាំ២០០៣

នោះគឺឧស្សាហកម្មកាត់ដេរ និងវិស័យទេសចរណ៍។ នេះជាប្រការដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈងាយទទួលរងគ្រោះដោយសារអស្ថិរភាពនិងវិបត្តិផ្សេងៗពីក្រៅប្រទេស។ ក្នុងន័យនេះយើងមានសេចក្តីត្រូវការដ៏ចាំបាច់ ក្នុងការពង្រឹង និងពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចជាតិ ដោយប្រើប្រាស់នូវសក្តានុពលភាពសេដ្ឋកិច្ចក្នុងវិស័យផ្សេងៗទៀតឱ្យកាន់តែច្រើន។ និយាយនេះគឺចង់សំដៅទៅលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ដែលមានសក្តានុពលកំណើនដ៏ធំធេង ហើយថែមទាំងអាចផ្តល់ឥទ្ធិពលជាវិជ្ជមានយ៉ាងឆាប់រហ័ស ទៅលើកិច្ចការខិតខំប្រឹងប្រែងរបស់យើង ដើម្បីលើកកំពស់ជីវភាពរបស់ប្រជាជននៅទីជនបទទៀតផង។

**២២.** រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើការបង្កើនឥទ្ធិពលផ្ទៃក្នុងឱ្យបានជាអតិបរមា និងការពង្រីកចំណងទាក់ទងខាងផ្នែកសេដ្ឋកិច្ចយ៉ាងទូលំទូលាយ ឱ្យទៅជាមធ្យោបាយមួយសំរាប់បង្កើនល្បឿនអភិវឌ្ឍន៍វិស័យកសិកម្មនិងតំបន់ជនបទ។ គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាលបានផ្តោតសំខាន់លើការលើកស្ទួយតួនាទីរបស់ផ្នែកកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយដែលអាចផ្តល់ថាមពលបន្ថែមដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានកំណត់យ៉ាងច្បាស់ ដើម្បីបង្កើនការប្រើប្រាស់ធនធាន ក្នុងស្រុកសំរាប់អនុវត្ត ពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ធានានូវនិរន្តរភាព នៃ កំណើនសកម្មភាពសេដ្ឋកិច្ច បង្កើតការងារនិងបង្កើនប្រាក់ចំណូលនៅជនបទព្រមទាំងធានាសន្តិសុខស្បៀងសំរាប់ ប្រជាពលរដ្ឋទូទៅហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញកសិផល[5]។ កំណែទំរង់ស្ថាប័ន ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជនបទដែលពាក់ព័ន្ធជាមួយនឹង វិស័យកសិកម្ម រួមមានការរៀបចំឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ជនបទ ។ ស្ថាប័ន អន្តរក្រសួងជាគន្លិះរួមមាន ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលសំរបសំរួលក្នុងការប្រមូលទិន្នន័យ និង ការវិភាគ ផ្តល់ឱ្យមានវេទិកា សំរាប់ដោះស្រាយបញ្ហា ផ្សេងៗ និងកំណត់អាទិភាពនិងសំរួលការអនុវត្តន៍ក្នុងវិស័យ គន្លិះទាំងពីរនេះ (វិស័យកសិកម្ម និង វិស័យអភិវឌ្ឍន៍ជនបទ) ។

### ២.៣ ការអភិវឌ្ឍន៍វិស័យឯកជន

**២៣.** ក្នុងនិតិកាលទី ៣ នៃរដ្ឋសភាកន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវលទ្ធផលធំៗ រួមមានការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ ការពង្រឹងការគោរព សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ ការពង្រឹងអភិបាលកិច្ចតាមរយៈកំណែទម្រង់រដ្ឋ ការធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចក្នុងកម្រិតពីរខ្ទង់ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការបញ្ចប់ស្ទើរតែទាំងស្រុងនូវការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ការពង្រឹងភាពជាដៃគូ និង ការពង្រឹងវិស័យឯកជន។

**២៤.** វិស័យឯកជន បានក្លាយទៅជា "ក្បាលម៉ាស៊ីនពិតប្រាកដនៃកំណើនសេដ្ឋកិច្ច" និងបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវ័ន្ត និងក្នុងវិស័យហិរញ្ញវត្ថុ ហើយរាជរដ្ឋាភិបាលជាអ្នករៀបចំយុទ្ធសាស្ត្រ ដើម្បីបង្កើតបរិស្ថានធុរកិច្ចឱ្យកាន់តែប្រសើរ សម្រាប់វិស័យឯកជន និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍន៍។ អាទិភាពពិសេសកាលពីនីតិកាលទី ៣ ដែលផ្តោតលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួម សម្រាប់ការអភិវឌ្ឍន៍វិស័យឯកជន រួមមានវិធានការណ៍ពង្រឹង

[5] សុន្ទរកថា ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្នុងឱកាសផ្សព្វផ្សាយរបាយការណ៍អភិវឌ្ឍពិភពលោក ស្តីពីវិស័យកសិកម្មសំម្រាប់ការអភិវឌ្ឍន៍ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ (World Development Report 2008 on Agriculture For Development, World Bank)

អភិបាលកិច្ចទាំងក្នុងវិស័យសាធារណៈ និងក្នុងវិស័យឯកជន សម្រួលពាណិជ្ជកម្ម និងកែលំអបរិយាកាសវិនិយោគ និងជម្រុញអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងតម្រូវការនៃទីផ្សារ។ ស្ថាប័នឯកជន ត្រូវបានលើកទឹកចិត្តឱ្យចូលរួមនៅក្នុងវិស័យអាទិភាពទាំង ៦ រួមមាន ការអភិវឌ្ឍន៍វិស័យកសិកម្ម និងកសិឧស្សាហកម្ម ក្នុងនោះផ្ដល់អាទិភាពលើការដោះស្រាយទឹកសម្រាប់កសិកម្ម ការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដឹកជញ្ជូន និងទូរគមនាគមន៍ ការអភិវឌ្ឍន៍វិស័យថាមពល និងអគ្គិសនី វិស័យអតិពលកម្ម និងឧស្សាហកម្មកែច្នៃសម្រាប់ការនាំចេញ វិស័យឧស្សាហកម្មទេសចរណ៍ និងការអភិវឌ្ឍន៍ធនធានមនុស្ស។

**២៥.** គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើរតួជាអង្គភាពកណ្ដាល ដើម្បីទាក់ទាញនិងសម្រួលការវិនិយោគឯកជននៅកម្ពុជា។ វេទិកាចម្រុះកម្រិតខ្ពស់រវាងរាជរដ្ឋាភិបាលនិងផ្នែកឯកជន ត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ ១៩៩៩ ដែលបានគាំទ្រដោយក្រុមការងារចម្រុះតាមវិស័យរវាងរដ្ឋាភិបាលនិងផ្នែកធុរៈកិច្ចចំនួនប្រាំពីរ។ ដំណើរការនេះ ត្រូវបានពង្រឹងនិងពង្រីកជាបន្តទៀត នាខែសីហា ឆ្នាំ២០០៤ តាមរយៈការបង្កើតគណៈកម្មាធិការដឹកនាំកម្រិតខ្ពស់មួយ សម្រាប់ការអភិវឌ្ឍវិស័យឯកជន។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវដោយឡែកមួយចំនួន រួមមាន ការលើកសំណើនិងការអនុវត្តវិធានការទាំងឡាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ការសម្រួលផ្នែកពាណិជ្ជកម្ម ហើយដើម្បីជំរុញលើកទឹកចិត្តការអភិវឌ្ឍវិស័យឯកជន។

**២៦.** ការវិនិយោគរបស់ផ្នែកឯកជននៅកម្ពុជា ត្រូវបានធ្វើឡើងនៅក្នុងវិស័យជាច្រើន ប៉ុន្តែវិស័យដែលគួរឱ្យកត់សម្គាល់ច្រើនជាងគេនោះគឺ ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ ការងារសំណង់ ធនាគារ អាកាសចរណ៍ ព្រៃឈើ និងកសិដ្ឋានដំណាំ។ គម្រោងជារូបភាព សាងសង់-ដំណើរការ-ផ្ទេរ មួយចំនួន ត្រូវបានដំណើរការដោយផ្នែកឯកជន។ នៅពេលថ្មីៗនេះ ផ្នែកឯកជនបានចូលរួមយ៉ាងសកម្មផងដែរក្នុងវិស័យអប់រំកម្រិតឧត្ដមសិក្សា។ ប៉ុន្តែ លំហូរចូលនៃការវិនិយោគទៅក្នុងវិស័យអាទិភាព មានសភាពយឺតខ្លាំងជាអាទិ៍ វិស័យអាទិភាពមួយចំនួនដែលរាជរដ្ឋាភិបាលចាត់ទុកថា មានប្រៀបខ្លាំងក្នុងការប្រកួតប្រជែង និងអាចផ្ដល់ចំណូលខ្ពស់ ដូចជា កសិកម្ម ការកែច្នៃកសិផល ហេដ្ឋារចនាសម្ព័ន្ធ ។ល។

## ២.៤ សហគ្រាសខ្នាតតូច និងមធ្យម

**២៧.** រាជរដ្ឋាភិបាល បានកាត់បន្ថយនូវតម្រូវការអប្បរមាសម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងបានកាត់បន្ថយចំណាយក្នុងការចុះបញ្ជីក្រុមហ៊ុន។ ប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកែលម្អឱ្យមានលក្ខណៈសមញ្ញ។ កម្ចីដែលផ្ដល់ដោយស្ថាប័នហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និងមធ្យម បានកើនឡើងគួរឱ្យកត់សម្គាល់។ ចលនា "ភូមិមួយផលិតផលមួយ" នឹងត្រូវបានជម្រុញជាបន្តទៀត ដោយការបណ្ដុះគំនិតច្នៃប្រឌិត សហគ្រិនភាព និងជំនឿលើខ្លួនឯងនៅតាមទីជនបទ។ ចលនានេះ ជាក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដើម្បីភ្ជាប់ផលិតកម្មទៅនឹងទីផ្សារ រក្សាអត្តសញ្ញាណតំបន់ លើកទឹកចិត្តឱ្យមានគំនិតផ្ដួចផ្ដើមថ្មីៗ និងទូលំទូលាយ តាមរយៈពិពិធភាវូបនីយកម្មប្រភេទទំនិញឱ្យបានច្រើន។ រាជរដ្ឋាភិបាល ជម្រុញការធ្វើវិក្រឹត្យការបច្ចេកទេសចំពោះទំនិញ ដែលមានលក្ខណៈពិសេសនៅតាមតំបន់មួយចំនួន ក្នុងន័យពង្រឹងគុណភាព និងពង្រីកទីផ្សារដែលជាចំណុចស្នូលសម្រាប់លើកកម្ពស់ចលនានេះ ឱ្យមានការគាំទ្រ និងការចូលរួមកាន់តែច្រើនឡើង។

**២៨.** នៅក្នុងនិតិកាលទី ៤ នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងបន្តពង្រឹងបរិស្ថានធុរកិច្ច សម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ដោយផ្តោតលើទិដ្ឋភាពសំខាន់បួន គឺ **១. ក្របខណ្ឌច្បាប់ និងនិយ័តកម្ម** រួមមានការសម្រួលការចុះបញ្ជី ជាពិសេសតាមប្រព័ន្ធអ៊ីនធ័រណេត ការកំណត់នីតិវិធី និងគោលការណ៍សម្រាប់ការត្រួតពិនិត្យ និងបញ្ជាក់ពីផលិតផលនាំចេញ និងនាំចូល ការរៀបចំ និងអនុម័តអនុក្រឹត្យស្តីពីការសម្រួលពាណិជ្ជកម្ម តាមរយៈវិធីសាស្ត្រគ្រប់គ្រងហានិភ័យ **២. ការផ្តល់ហិរញ្ញប្បទាន** រួមមានការបង្កើតក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងការពង្រឹងអភិបាលកិច្ច និងរបាយការណ៍ហិរញ្ញវត្ថុ **៣. សកម្មភាពគាំទ្រសហគ្រាសធុនតូច និងមធ្យម** រួមមានការលើកស្ទួយនវានុវត្តន៍ និងបច្ចេកវិទ្យា ព្រមទាំងការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម និងការពង្រឹង និងពង្រីកសេវាគាំទ្រផ្សេងៗទៀត **៤. ការបញ្ចូលសហគ្រាសធុនតូច និងមធ្យម** ទៅក្នុងខ្សែសង្វាក់តម្លៃជាសកល និងការទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ។

**២៩.** សហគ្រាសតូចនិងមធ្យមដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងក្នុងការបង្កើតឱ្យមានការងារ និងប្រាក់ចំណូល ប្រកបដោយចីរភាពសម្រាប់ប្រជាជន ។ សហគ្រាសតូចនិងមធ្យម មានសមាមាត្រប្រមាណ ៩៩ភាគរយនៃសហគ្រាសទាំងអស់ ហើយស្រូបយកជិតពាក់កណ្តាលនៃការងារទាំងអស់ដែលបង្កើតឡើងដោយផ្នែកឯកជន។ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍សហគ្រាសតូច និងមធ្យម ដ៏ទូលំទូលាយមួយសម្រាប់កម្ពុជា ហើយថ្មីៗនេះ បានរៀបចំនូវកម្មវិធីអភិវឌ្ឍន៍សហគ្រាសតូចនិងមធ្យម។ លេខាធិការដ្ឋានពិសេសមួយសម្រាប់សហគ្រាសតូចនិងមធ្យម ត្រូវបានបង្កើតឡើងដើម្បីអនុវត្តគោលនយោបាយ និងកម្មវិធីនានា នៅក្នុងការងារនេះ។

**៣០.** សហគ្រាសតូចនិងមធ្យមជាធម្មតាស្ថិតនៅជាប់ប្រជាជនសាមញ្ញ និងផ្តល់ផលប្រយោជន៍ដល់សហគមន៍ជនបទក្នុងការកែច្នៃ និងតម្លៃបន្ថែមទៅលើផលិតផល ក៏ដូចជាការបង្កើតការងារ។ សហគ្រាសតូចនិងមធ្យមផ្តល់ផងដែរនូវការតភ្ជាប់យ៉ាងសំខាន់ទៅនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជាទៅនឹងសហគ្រាសធំៗ។ ដើម្បីជំរុញល្បឿននិងសម្រួលដល់សហគ្រាសតូចនិងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការដូចខាងក្រោម :

- ដាក់ឱ្យមាននូវវិធានការទាំងឡាយ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាសដំណើរការក្នុងបរិស្ថានធុរៈកិច្ចមួយមានផលចំណេញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរយៈពេលមធ្យម និងវែង
- បង្កើតប្រព័ន្ធពិសេសៗដើម្បីគាំទ្រស្ត្រីក្នុងធុរៈកិច្ច និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រី ឱ្យអាចប្រើប្រាស់សេវាកម្ម និងកម្មវិធីនានានៃការអភិវឌ្ឍសហគ្រាសតូចនិងមធ្យម
- កាត់បន្ថយនីតិវិធីការចុះបញ្ជីក្រុមហ៊ុន និងជួយក្នុងដំណើរការនៃការចាប់ផ្តើមរបស់សហគ្រាសតូចនិងមធ្យម
- បង្កើតស្ថាប័នស្តង់ដារជាតិនិងស្ថាប័នផលិតភាព ដើម្បីជួយធានាគុណភាពនៃផលិតផលក្នុងស្រុកនិងបង្កើនផលិតភាព
- ជំរុញគាំទ្រសេវាប្រឹក្សាដល់សហគ្រាសតូចនិងមធ្យម ដើម្បីជួយអភិវឌ្ឍបច្ចេកវិទ្យាទំនើបនៅក្នុងផលិតកម្ម ការកែលម្អគុណភាពផលិតផល ការគ្រប់គ្រងនិងការស្វែងរកទីផ្សារ
- ពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតច្បាប់នានាដែលពាក់ព័ន្ធនឹងរោងចក្រ តំបន់ឧស្សាហកម្ម ប៉ាតង់ និងការបង្កើតមុខទំនិញថ្មីៗ ខ្នាតនិងរង្វាស់រង្វាល់ និងសុវត្ថិភាពឧស្សាហកម្ម
- លើកកម្ពស់កិច្ចសហប្រតិបត្តការ ជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការជំរុញសហគ្រាសតូចនិងមធ្យម

## ២.៥ ការអភិវឌ្ឍន៍ជនបទ

**៣១.** ការអភិវឌ្ឍន៍ជនបទ ជាបញ្ហាសំខាន់បំផុតដើម្បីលើកកំពស់ក៏រិតជីវភាពរបស់ប្រជារាស្ត្រគ្រប់រូប និងដើម្បីកាត់បន្ថយភាពខុសគ្នារវាងចំណូលនៅជនបទ និងនៅទីក្រុង ហើយជាពិសេស ដើម្បីពង្រឹងការផ្សះផ្សារជាតិ និងសន្តិសុខផ្ទៃក្នុងប្រទេស។ រាជរដ្ឋាភិបាលបានចាត់ទុកកម្មវិធីអភិវឌ្ឍន៍ជនបទ ជាកិច្ចការគន្លឹះក្នុងការកំណត់នូវតំរូវការរយៈកាលខ្លីដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការបន្ទាន់ ហើយសំរាប់រយៈពេលវែងគឺធានាការរួមចំណែកតាមរបៀបប្រជាធិបតេយ្យរបស់ប្រជារាស្ត្រនៅតាមតំបន់ជនបទ ក៏ដូចជាក្នុងប្រទេសទាំងមូល ។ ការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនិងបង្កើនផលិតផលក្នុងស្រុក បង្កើនការងារ បង្កើតមូលដ្ឋានសំរាប់ការកសាងរោងចក្រកែច្នៃកសិផលនិងសំរាប់ការនាំចេញ ហើយនិងរួមចំណែកយ៉ាងខ្លាំងក្លា ក្នុងការធានាសន្តិសុខខាងផ្នែកម្ហូបអាហារ និងការផលិតសំរាប់ជំនួសទំនិញនាំចូល ព្រមទាំងអាចធានានូវស្ថេរភាពថ្លៃម្ហូបអាហារដែលជាកត្តា ដ៏សំខាន់ក្នុងការពង្រឹងតុល្យភាពម៉ាក្រូសេដ្ឋកិច្ច[៦] ។ គោលដៅទាំងនេះក៏បានឆ្លើយស្របទៅនឹងសំណូមពររបស់អង្គការសង្គមស៊ីវិល មួយចំនួនរៀបចំដោយមជ្ឈមណ្ឌលសិក្សានិងអភីវឌ្ឍន៍កសិកម្មនៅកម្ពុជា (CEDAC) ដែលបានធ្វើការអំពាវនាវចំពោះរាជរដ្ឋាភិបាល និងស្ថាប័ន ពាក់ព័ន្ធ មាន៩ចំណុចទាក់ទិននឹងបញ្ហាស្បៀងអាហារ[៧] ។

**៣២.** ការសិក្សាមួយនៅកម្ពុជាបានសំគាល់ថា **ការអភិវឌ្ឍន៍ជនបទ** មិនមែនដូចពីដើមទៀតទេ គឺមិនមែនត្រឹមតែការបង្កើនផលិតកម្ម ឬការបែងចែកផលិតផលប៉ុណ្ណោះទេ។ អភិវឌ្ឍន៍ជនបទត្រូវមាននិរន្តភាព, យុត្តិធម៌សង្គម, ការផ្សះផ្សា, សន្តិភាព, ប្រជាធិបតេយ្យ, អភិបាលកិច្ចល្អ, បំបាត់អំពើពុករលួយ, តម្លាភាព, ស្មើភេទគ្នា, ការចូលរួម នឹងពង្រឹងសង្គមស៊ីវិល, និង ភាពជាដៃគូជាមួយគ្រឹស្ថានឯកជន និងសាធារណៈ[8] ។ ហេតុដូច្នេះហើយ ការងារអភិវឌ្ឍន៍ជនបទ មានចរិតដំណើរការជាថាមវ័ន្តអភិវឌ្ឍន៍ជាសកម្មឈានមុខ ត្រូវឆ្លើយតបទៅនិងការផ្លាស់ប្តូរ និងការវិវត្តន៍ជាបន្តបន្ទាប់ក្នុងបរិកានៃការអភិវឌ្ឍន៍ទូលំទូលាយ និងបោះជំហានទៅមុខជាប្រចាំ។ ការវិនិយោគនៅជនបទ តំរូវឱ្យយើងពិនិត្យមើលគ្រប់វិស័យ ដែលឆ្លើយតបទៅនឹងតំរូវការមូលដ្ឋាន មានជាពិសេស វិស័យកសិកម្ម ការងារគ្រប់គ្រងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនជនបទ ទឹកស្អាតនិងអនាម័យ អប់រំ សុខាភិបាល បច្ចេកវិទ្យាទូរគមនាគមន៍ពតិមាន ព្រមទាំងសេវាសង្គមផ្សេងៗទៀត ។ ដើម្បីធានាការអភិវឌ្ឍន៍ជនបទឱ្យមានចិរភាព សកម្មភាពឬកន្សោមការងារ អទិភាពចាំបាច់ត្រូវមានលក្ខណៈជាពហុវិន័យ និងពហុវិស័យតំរង់ទិសទៅរកការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ តាមរយៈការអភិវឌ្ឍន៍វិស័យសង្គមផង អភិវឌ្ឍន៍សេដ្ឋកិច្ចនៅជនបទផង និងការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ចល្អផង ។

---

[6] កម្មវិធីជាតិសំរាប់នីតិសម្បទានិងអភិវឌ្ឍកម្ពុជា – កម្មវិធីតាមផ្នែក កសិកម្ម និងការអភិវឌ្ឍន៍ជនបទ ទំព័រ៣១

[៧] ដកស្រង់កាសែត **កោះសន្តិភាព** លេខ៦៤៧៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ – ក្រុមសង្គមស៊ីវិលអំពាវនាវ៩ចំណុចទាក់ទិននឹងបញ្ហាស្បៀងអាហារ : ទី១-គាំទ្របង្កើនការផ្សព្វផ្សាយប្រព័ន្ធប្រពលវប្បកម្មដំនាំស្រូវតាមគោសលការណ៏ធម្មជាតិឱ្យបានទូទាំងប្រទេស ។ ទី២- បង្កើននិងពង្រីកនូវសកម្មភាពកសិករក្នុងការផលិតនិងទុកដាក់ពូជស្រូវនៅតាមសហគមន៍។ ទី៣- ជំរុញនូវការផលិត និងប្រើប្រាស់ជីធម្មជាតិឱ្យបានទូលំទូលាយ ។ ទី៤- ពង្រឹងនិងពង្រីកការវិនិយោគលើការស្តារនិងអភីវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រខ្នាតតូចនិងមធ្យម ។ ទី៥- បង្កើនសមត្ថភាពសហគមន៍ក្នុងការស្តុកស្រូវ ជាពិសេសសមត្ថភាពចងក្រងសហគមន៍ និងផ្តល់ទុនប្រាក់កំចីដែលមានការប្រាក់ទាប ។ ទី៦- បញ្ជ្រាបដល់ការបណ្តុះបណ្តាល អំពីកសិកម្មនៅក្នុងកម្មវិធីអប់រំជនបទ ជាពិសេសចាប់ពីថ្នាក់ទី៩ឡើងទៅ ដើម្បីផ្តល់ឱកាសឱ្យសិស្សដែលចាប់អារម្មណ៏ពីមុខរបរកសិកម្មងាយស្រួលក្នុងការចាប់យកជំនាញ ។ ទី៧- ពង្រឹងឱកាសទីផ្សារជូនដល់កសិករ ដើម្បីអាចឱ្យពួកគាត់ងាយស្រួលក្នុងការលក់ផលិតផលកសិកម្មក្នុងតំលៃសមរម្យ ។ ទី៨- ផ្តល់លទ្ធភាពលើការទុកដីសំរាប់ធ្វើសម្បទានសង្គមកិច្ច ជាជាងធ្វើសម្បទានសេដ្ឋកិច្ច ។ទី៩- បង្កើនការភ្ញាក់រលឹកឱ្យបានទូលំទូលាយដល់កសិករ និងអាជ្ញាធរមូលដ្ឋានក្នុងគោលបំណងជំរុញកុំឱ្យមានការលក់ដីស្រែ ។

[8] Joseph Mullen. -{នយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសំរាប់លប់បំបាត់ភាពក្រីក្រនៅកម្ពុជាក្រោយជំលោះ FAO 5 / 1/ 00 } អង្គការសហប្រជាជាតិ សំរាប់ស្បៀងនិងពលកម្ម (FAO-2000)

៣៣. **ការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ** នៅប្រទេសកម្ពុជាក៏ដូចជាប្រទេសនានាក្នុងតំបន់អាស៊ីទាំងមូល, ការលប់បំបាត់ទុរភិក្ស, ការកាត់បន្ថយភាពក្រីក្រ ចាំបាច់ត្រូវតែអនុវត្តកម្មវិធី ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចឱ្យចំគោលដៅសំដៅទីជនបទដាច់ស្រយាល។ **ការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅជនបទ** ប្រកបដោយចិរភាពត្រូវពិនិត្យទៅលើសកម្មភាពការងារ ក្នុងក្របខ័ណ្ឌគ្រប់វិស័យពាក់ព័ន្ធ ជាអាទិ៍ កសិកម្ម និងធនធានទឹកសំរាប់កសិកម្ម សុខាភិបាល បរិស្ថាន ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គមនាគមន៍ដឹកជញ្ជូនជនបទ ដីធ្លី ជាដើម។ ការងារនៃវិស័យទាំងនេះបានដាក់ចេញនូវកិរិតយុទ្ធសាស្ត្រ និងរបៀបវារៈនៃគោលនយោបាយ ក្នុងបញ្ហាគន្លឹះជាច្រើន រួមជាមួយគោលដៅជាទូទៅ នៃការបង្កើតប្រាក់ចំណូលសំរាប់ប្រជាជននៅតំបន់ជនបទទាំងនោះរួមមាន ដី ទឹក កសិកម្ម ព្រៃឈើ ការនេសាទ និងការដឹកជញ្ជូនជាដើម។ ការកែលំអ និងប្រសិទ្ធភាពនៃការអនុវត្តសកម្មភាព ក្នុងវិស័យទាំងនេះ នឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើង ដល់ផ្នែកផ្សេងៗនៃភាពក្រីក្រ ឧទាហរណ៍ ដូចជាតាមរយៈការទទួលបាននូវសេវាជាមូលដ្ឋានល្អជាងមុន ហើយក៏មានទំនាក់ទំនងរវាងសកម្មភាពក្នុងវិស័យផ្សេងទៀត ដូចជាការធ្វើវិមជ្ឈការ និងការរស់នៅតំបន់ជនបទ។ ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅតាមជនបទ ត្រូវពឹងផ្អែកលើការកាត់បន្ថយភាពក្រីក្រលើវិស័យផ្សេងទៀត។ ភាពទន់ខ្សោយលើផ្នែកសុខភាព ការអប់រំ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងផលិតភាពមានកំរិតទាប ជាហេតុនាំឱ្យអ្នករស់នៅ ជនបទឈានទៅរកភាពក្រីក្រ។ ការថែរក្សាសុខភាពបឋមគឺមានសារៈសំខាន់ណាស់សំរាប ប្រជាជនរស់នៅជនបទ។ ម្យ៉ាងទៀតការកំណត់តំបន់គោលដៅ ក៏មានសារៈសំខាន់ណាស់ និងគួរចាត់ទុកជា វិធានការយុទ្ធសាស្ត្រមួយ ដើម្បីជោគជ័យនៃការងារបង្កើនជីវភាពរស់នៅនៅជនបទ។ ការកំណត់តំបន់គោលដៅនេះមិនមែនបានន័យថាយើងបោះបង់ចោល និងមិនមានសកម្មភាពអនុវត្តការងារអភិវឌ្ឍន៍ជនបទ នៅតំបន់ឯទៀតនោះទេ។ ប៉ុន្តែយើងគួរតំរង់ការយកចិត្តជាអាទិភាពលើតំបន់ដែលកំពុងជួបប្រទះនូវការប្រឈមនឹងភាពក្រីក្រខ្លាំង និងងាយរងគ្រោះជាងគេ ជាពិសេសតំបន់ព្រំដែន តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ជនជាតិដើមភាគតិចជាដើម ព្រោះថាតំបន់ទាំងនេះមិនទាន់មានការអភិវឌ្ឍន៍ទូលំទូលាយនៅឡើយ បញ្ហាធនធានធម្មជាតិ និងបរិស្ថានកំពុងរងការបំផ្លាញរិចរិលជាបន្តបន្ទាប់ ហេដ្ឋារចនាសម្ព័ន្ធមិនទាន់គ្រប់គ្រាន់ បញ្ហាគ្រោះថ្នាក់ដោយសារគ្រាប់មីន សេវាបំរើសង្គមសេដ្ឋកិច្ចនៅមានកំរិត ។

## ២.៦ វិស័យសន្តិសុខស្បៀង

៣៤. **សន្តិសុខស្បៀង និងអាហារូបត្ថម្ភ** គឺជាអាទិភាពអភិវឌ្ឍន៍ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលប់បំបាត់ភាពក្រីក្រនិងភាពស្រេកឃ្លាន ហើយដែលជាគោលដៅទី១ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ២០០៦-២០១០ ចែងថា : *សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជាគោលដៅគន្លឹះដើម្បីធានាឱ្យបានថា "ត្រឹមឆ្នាំ ២០១០ ប្រជាពលរដ្ឋកម្ពុជាក្រីក្រនិងអសន្តិសុខស្បៀង នឹងមានលទ្ធភាពល្អប្រសើរច្រើនទាំងផ្នែករូបវ័ន្តនិងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាពនិងមានជីវជាតិគ្រប់គ្រាន់ ដើម្បីបំពេញតំរូវការរបបអាហារ និងចំណង់ចំណូលចិត្ត នៅគ្រប់ពេលវេលាទាំងអស់សំរាប់ជីវិតរស់នៅយ៉ាងសកម្មនិងមានសុខភាពមាំមួន "* [៩] ។ **ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា២០០៨-២០១២** គឺជាឯកសារយោងស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលជាជាបញ្ហាពហុវិស័យ ដែលបានរៀបចំចងក្រងឡើងដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដោយសហការជាមួយក្រុមការងារបច្ចេក

---

[៩] ***ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨-២០១២*** រៀបចំដោយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ — រាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០០៨ ។

ទេសសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។ គោលបំណងនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០០៨-២០១២ មានគោលបំណងប្រាំ ។ គោលបំណងនីមួយៗ បានកំណត់វិស័យជាច្រើនសំរាប់ធ្វើអន្តរាគមន៍ និងមានសកម្មភាពជាអាទិភាពជាក់លាក់ជាច្រើនដែលត្រូវអនុវត្ត ។ គោលបំណងនីមួយៗ នឹងតំរូវឱ្យមានការវិនិយោគលើសេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាពក្នុងវិស័យនានាជាច្រើនរបស់ក្រសួង និងស្ថាប័នសំរបសំរួលរបស់រាជរដ្ឋាភិបាល ។

- **គោលបំណងទី១:** ក្រុមគ្រួសារអសន្តិសុខស្បៀង **បង្កើនភាពមានស្បៀង** តាមរយៈផលិតកសិកម្ម និងបសុសត្វ និងតាមរយៈធនធានជលផល និងអនុផលព្រៃឈើ
- **គោលបំណងទី២:** ក្រុមគ្រួសារអសន្តិសុខស្បៀង **បង្កើនភាពទទួលបានស្បៀង** តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- **គោលបំណងទី៣:** ក្រុមគ្រួសារអសន្តិសុខស្បៀង **កែលំអការប្រើប្រាស់ និងការទាញស្រូបស្បៀង** ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ ជំងឺដង្កាត់ និងមរណភាព ជាពិសេសក្នុងចំណោមស្ត្រីនិងកុមារ
- **គោលបំណងទី៤:** កែលំអបណ្តាញសុវត្ថិភាពសង្គម និងលើកកំពស់សមត្ថភាពរបស់ក្រុមគ្រួសារអសន្តិសុខស្បៀងក្នុងការដោះស្រាយហានិភ័យផ្សេងៗ នឹងជួយ**បង្កើនស្ថេរភាពនៃការផ្គត់ផ្គង់ស្បៀង**
- **គោលបំណងទី៥:** **កែលំអបរិស្ថានគោលនយោបាយ និងស្ថាប័ន** ដើម្បីសំរេចបានការកែលំអសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ។

**៣៥.** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ គឺជាស្ថាប័នសំរបសំរួលការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដើម្បីផ្តល់ការគាំទ្រដល់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនាពេលបច្ចុប្បន្ននិងទៅអានាគត។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ធ្លាប់បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅឆ្នាំ ១៩៩៩ និងឆ្នាំ២០០៣ ។ នៅចុងឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ និង ក្រសួងផែនការ ជាសហប្រធាន និង មានអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ ជាអ្នកសំរបសំរួលរួម។ រចនាសម្ព័ន្ធសំរបសំរួលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ទាំងនេះ ទាមទារឱ្យមានការអភិវឌ្ឍ និងគាំទ្របន្ថែមទៀត ។

## ២.៧ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម

**៣៦.** គោលគំនិតផ្តួចផ្តើមរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ត្រូវបានលើកឡើងនៅក្នុងគោលនយោបាយយុទ្ធសាស្ត្រចតុកោណ នានីតិកាលទី ៣ ដោយផ្តោតខ្លាំងទៅលើក្រុមគោលដៅដែលជាមន្ត្រីរាជការ បុគ្គលិក និងកម្មករ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងបង្កើនអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច ដោយពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការជាតិ និងអន្តរជាតិនានា នៅក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ដើម្បីជួយដល់អ្នករងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ និងពង្រីកកម្មវិធីលើកកំពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថាដែលគ្មានទីពឹង អតីតយុទ្ធជន និងគ្រួសារ។

**៣៧.** ក្នុងការបន្តជម្រុញអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពសង្គម រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពទៅលើការកែលម្អឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករ និងនិយោជិក ការជម្រុញអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ការអនុវត្តគោលការណ៍ផ្តល់របបសោធននិវត្តន៍សម្រាប់អ្នកបាត់បង់សមត្ថភាពពលកម្ម និងអ្នកនៅក្នុងបន្ទុក និងជម្រុញបន្ថែមទៀតនូវការការពារដល់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ និងធានាឱ្យនិយោជិកទាំងអស់ ទទួលបាននូវការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ។ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការជួយឧបត្ថម្ភឱ្យបានជិតដល់ ចំពោះជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលនឹងបន្តជួយគាំទ្រដល់យោធិន និងមន្ត្រីរាជការចូលនិវត្តន៍ តាមរយៈប្រព័ន្ធសោធននិវត្តន៍មួយ ដែលមានវិសាលភាពទូលំទូលាយ ដោយបន្តជម្រុញអនុវត្ត បេឡាជាតិសន្តិសុខសង្គម។

## ២.៨ ឱកាសផលិតស្បៀងនៃវិស័យកសិកម្ម

**៣៨. តំរូវការស្បៀងលើពិភពលោកនិងសក្តានុពលនៃកសិកម្មនាំចេញរបស់កម្ពុជា:** ស្ថានភាពភូមិសាស្ត្រនៃប្រទេសកម្ពុជាមានភាពអំណោយផល សំរាប់ការផលិតផលកសិកម្ម មិនត្រឹមដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុកប៉ុណ្ណោះទេ តែក៏យើងមានសក្តានុពលនាំចេញកសិផលទៅបំពេញតំរូវការនៅក្រៅប្រទេសបានដែរ ។ នៅក្នុងចំណោមប្រទេសក្រីក្រមានចំណូលទាបជាង៧០ប្រទេស ចំនួនប្រជាជនដែលស្រេកឃ្លានស្បៀងកើនឡើងពី ៨០៤លាននាក់ នៅឆ្នាំ២០០៥ ដល់៨៤៩លាននាក់ នៅឆ្នាំ២០០៦ [10] ហើយចំនួននេះអាចនឹងកើនឡើងទៀត ដោយថាមូលហេតុស្បៀង ជីបង្កបង្កើនកសិផល ប្រេង និង មធ្យោបាយដឹកជញ្ជូនឡើងថ្លៃ រួមទាំងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើសកលលោកដែលអាចកាត់បន្ថយការនាំចូល។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ក៏គំលាតនៃការបែងចែកស្បៀង មានការថយចុះ (Food Distribution Gap) - ជាសូចនាករទទួលស្បៀង ដែលបានន័យថាទោះចំនួននៃអ្នកប្រឈម និងអសន្តិសុខស្បៀងកើនឡើងក៏ដោយ ក៏ទំហំគ្រោះថ្នាក់មានកំរិតទាបនៅឆ្នាំ២០០៦ ជាងឆ្នាំ២០០៥ ។ តាមការព្យាករ នៅឆ្នាំ២០១៦ ចំនួនអ្នកខ្វះស្បៀង និងមានការថយចុះនៅគ្រប់តំបន់ ។ គំលាតអាហារូបត្ថម្ភជាមធ្យម (Average Nutrition Gap) ដែលជាសូចនាករនៃការផ្គត់ផ្គង់ស្បៀង ស្មើ ១៣.៥លានតោន (ជាគ្រាប់ធញ្ញជាតិ) នៅ២០០៦ និងឡើងដល់ ១៤លានតោននៅឆ្នាំ២០១៦ ។ ៨៥% នៃគំលាតនេះ មាននៅតំបន់ឧបទ្វីបអាហ្វ្រិកសាហារ៉ា , ១៤% នៅទ្វីបអាស៊ី និង ១% នៅតំបន់ក្រីក្រនៃអាមេរិកឡាតាំង និងនៅការិបីន ។ តាមការប៉ាន់ស្មាន កំលាតនៃការបែងចែកស្បៀងនៅឆ្នាំ២០០៦ មាន ២៧លានតោន នៅលើប្រទេសទាំង៧០ តែនឹងថយចុះ ជិត២៦លានតោននៅឆ្នាំ២០១៦ ។ តាមការសិក្សាស្រាវជ្រាវនេះចំណាត់ជាអ្នកស្រេកឃ្លានស្បៀងគឺរាប់ជនណាដែលទទួលទានអាហារមានថាមពលតិចជាង២១០០កាឡូរី/១ថ្ងៃ។ គំលាតនៃការបែងចែកស្បៀង គឺជាចំនួនបរិមាណស្បៀង ដែល ត្រូវការបំពេញបន្ថែម ដល់ក្រុមជនអ្នកខ្វះ អាហារូបត្ថម្ភ ។

**៣៩.** តាមការវិភាគទៅលើតំរូវការស្បៀង[11] និងបណ្តាប្រទេសផលិតស្បៀងដែលមានលទ្ធភាពនាំចេញ ប្រទេសកម្ពុជាអាចមានលទ្ធភាពចូលរួមចំណែកក្នុងការផលិតស្រូវនាំចេញបំពេញតំរូវការ ទោះបីទំហំផ្ទៃដីកសិកម្មស្រូវមានតែជាង២,៥លានហិកតាក៏ដោយ ។ ជាមធ្យម តំរូវការស្បៀងលើពិភពលោកដែលត្រូវការនាំចូលទៅប្រទេសផ្សេងៗមានប្រមាណ ២៧-៣០លានតោន

---

[10] Meade, Rosen and Shapouri. *Food Security Assessment, 2006,* A report from the Economic Research Service USDA, Agriculture and Trade Report, GFA- 18 June 2007. www.ers.usda.gov

[11] Source: ***World Agricultural Supply and Demand Estimates.*** WASDE-457, April 9, 2008. Waob ISSN-9089, US Department of Agriculture, WASDE-457, April 9, 2008, Washington DC.

ក្នុង១ឆ្នាំ (២០០៥-២០០៧)។ ប្រទេសកម្ពុជា យើងមានសក្តានុពលធំធេងណាស់ បើប្រៀបធៀបនិងប្រទេសជិតខាង ក្នុងតំបន់ និង ក្នុងពិភពលោក ជាពិសេស ធនធានធម្មជាតិ ធនធានរ៉ែ លើដី ក្រោមទឹក ក្រោមដី សម្បត្តិវប្បធម៌សំបូរបែប ដែលជាប្រភពធនធាន នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ លើវិស័យកសិកម្ម កម្ពុជាផលិតស្រូវបានជាង៦,៧លានតោន (២០០៧) និងអាចនាំចេញស្រូវជាង២លានតោន នៅលើផ្ទៃដីជាង ២.៦លានហិកតា ក្នុងទិន្នផលតែ២.៦តោន/ហិកតាប៉ុណ្ណោះ។ ថៃនិងវៀតណាមជាប្រទេសនាំចេញអង្ករទៅបរទេសលំដាប់លេខ១និងលេខ២ ប្រមាណពី១០ ទៅ១៥លានតោន លើផ្ទៃដីពី ៨ ទៅ ១០លានហិកតា ក្នុងទិន្នផល ៣-៥តោន/ហិកតា ។ ប្រជាពលរដ្ឋគេមានច្រើន (៧០-៨៥លាននាក់) ផលិតផលដែល គេ ផលិតបានត្រូវរក្សាទុកសំរាប់ផ្គត់ផ្គង់ក្នុងស្រុក ។ ដោយឡែកនៅកម្ពុជា យើងមានជាង១៤លាននាក់ យើងត្រូវការស្រូវតែជាង ៤លានតោន ។ ដូច្នេះបើយើងអាច បង្កើនការដាំដុះបាន ២ដង និងប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ និងបង្កើនទិន្នផលពី២.៦តោន ទៅជាង ៣-៤តោន/ហិកតា គឺយើងអាចផលិតបានយ៉ាងតិចក៏ ពី ១០លានតោន ទៅ ១៥លានតោនក្នុង១ឆ្នាំ ។ ដូច្នេះកម្ពុជា អាចមានលទ្ធភាពនាំចេញអង្ករ ពី៦ ទៅ១០លានតោនជាស្រូវក្នុង១ឆ្នាំ ។

៤០. ប្រទេសមួយចំនួនមានការចាប់អារម្មណ៍ក្នុងការនាំស្រូវអង្ករ ជាពិសេស អង្ករសរីរាង្គ ចេញពីប្រទេសកម្ពុជា ជាអាទិ៍ មានសហភាពអឺរ៉ុប ប្រទេសចិន ប្រទេសនៅតំបន់នៅមជ្ឈិមបូព៌ា និងអាហ្វ្រិក ជាដើម ។ ប៉ុន្តែទោះបីជាយើងមានសក្តានុពលយ៉ាងនេះក្តី កម្ពុជានូវតែប្រឈមនឹងបញ្ហាមួយចំនួនក្នុងការនាំចេញអង្ករទៅក្រៅប្រទេស ។ បញ្ហាគុណភាព បញ្ហាកង្វះខាតបច្ចេកវិទ្យាគ្រប់គ្រងនិងថែរក្សានៅក្រោយការប្រមូលផល[12] ។ ថ្នាក់ដឹកនាំ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ទទួលស្គាល់ពីភាពចាំបាច់នៅក្នុងការបង្កើនស្តង់ដារនិងបង្កើនសមត្ថភាពនៅក្នុងការចេញវិញ្ញាបនប័ត្របញ្ជាក់ពីគុណភាព និង ការបង្កើតសហគមន៍អភិវឌ្ឍន៍ ដើម្បីងាយស្រួលនៅក្នុងការប្រមូលស្រូវក៏ដូចជាការអភិវឌ្ឍន៍ផ្នែកកសិកម្មផងដែរ។ ការប្រឈមមួយទៀតគឺការខ្វះខាតបច្ចេកវិទ្យាក្រោយការប្រមូលផល ដូចជាការហាលសំងួត ឃ្លាំងស្តុក រួមនិងម៉ាស៊ីនកិនស្រូវតូច វាធ្វើឱ្យបែកគ្រាប់អង្ករច្រើនកំណាត់ ដែលនាំឱ្យពិបាកក្នុងការនាំចេញ ។ ប្រទេសកម្ពុជាមានពូជស្រូវចំនួនជាង៤០០០ពូជ ដែលក្នុងនោះមានពូជ ស្រូវក្រអូបចំនួន២៣៧ពូជ ។ ក្រសួងកសិកម្ម បានធ្វើការផ្សព្វផ្សាយចំនួន៣៧ពូជឱ្យប្រជាជនធ្វើការដាំដុះ។

## ២.៩ ការកាត់បន្ថយភាពក្រីក្រពាក់កណ្ដាលនាឆ្នាំ ២០១៥

៤១. លក្ខណៈពិសេសមួយក្នុងដំណើរអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងរយៈពេល ៣ ទសវត្សកន្លងមកដែលផ្ទុយពីប្រទេសមួយចំនួនដែលទើបនឹងងើបចេញពីសង្គ្រាមស៊ីវិល គឺប្រទេសកម្ពុជាបានគេចផុតចេញពីការវិលទៅរកជម្លោះរ៉ាំរ៉ៃជាថ្មី និងការរក្សាស្ថេរភាពនៃកំណើន។ ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចម្រើន ឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍ ប៉ុន្តែនឹងត្រូវមានការខិតខំបន្ថែមទៀតក្នុងទសវត្សបន្ត។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក ប្រទេសកម្ពុជាបានបន្ត និងធ្វើឱ្យមានការរីកចម្រើនសំខាន់ៗជាច្រើន នៅក្នុងការអនុវត្តន៍ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលមានទិសដៅសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចដ៏យូរអង្វែង និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

---

[12] ឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ —ស្តីពី បញ្ហាគុណភាពនាំឱ្យអង្ករកម្ពុជាពិបាកនាំចេញទៅក្រៅប្រទេស - ដកស្រង់ចេញពីកាសែតកោះសន្តិភាព ចេញថ្ងៃសុក្រ ទី៣១ ខែតុលា ឆ្នាំ២០០៨ ឆ្នាំទី១៦ លេខ៤៧៣០ ។

៤២. ប៉ុន្តែ ទោះបីជាកំណើនសេដ្ឋកិច្ចដែលមានលក្ខណៈថេរ ក្នុងអំឡុងមួយទសវត្សកន្លងមកក៏ដោយ ក៏ភាពក្រីក្រមានការថយចុះតែពី ៣៩ % មក ៣៦ % ក្នុងរវាងឆ្នាំ ១៩៩៤ និង ១៩៩៩ ប៉ុណ្ណោះ[១៣]។ ការរីកចម្រើននៅតំបន់ជនបទ តាមមិនទាន់នឹងកំណើនរបស់ប្រជាជន ហើយក៏មាននិន្នាការគួរឱ្យព្រួយបារម្ភ នៃការកើនឡើងនូវអត្រាគ្មានការងារធ្វើនៅតំបន់ជនបទ និងកង្វះការរីកចម្រើនលើការងារក្រៅពីកសិកម្ម។ គិតមកត្រឹមឆ្នាំ ២០០៣ ក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា បានធ្វើទិទស្សន៍ថា ប្រសិនបើនិន្នាការកន្លងមកនៅតែបន្ត នោះឧប្បត្តិហេតុនៃភាពក្រីក្រនឹងថយចុះដល់ ២៨ % មុនដំណាច់ឆ្នាំ ២០១៥។ ធនាគារពិភពលោក[១៤] បានប្រមើលទុកថា ប្រសិនបើប្រទេសកម្ពុជានៅតែបន្តការកើនឡើងជាមួយអត្រារួមដដែល (៧,១ %) និងទម្រង់កំណើនក្នុងវិស័យដែលមានក្នុងទសវត្សកន្លងទៅនោះ ភាពក្រីក្របាក់ដូចជានឹងធ្លាក់ចុះក្នុងអត្រាទាប ហើយប្រទេសកម្ពុជាមិនអាចសម្រេចគោលដៅក្នុងការកាត់បន្ថយភាពក្រីក្របានពាក់កណ្តាល នៅរវាងឆ្នាំ ២០១៥ ឡើយ។ ជាការច្បាស់លាស់ ការថយចុះនៃភាពក្រីក្រនេះ ពុំអាចបានដល់ចំនុចដៅដែលបានដាក់ចេញ ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យមកនៅត្រឹម ១៩,៥ % នោះទេ។

៤៣. ដូច្នេះ ការសម្រេចបានចំនុចដៅនៃគោលដៅអភិវឌ្ឍន៍សហវត្សកម្ពុជា នឹងទាមទារឱ្យមានកំណើនសេដ្ឋកិច្ចលឿនជាងមុន និងកាត់បន្ថយភាពក្រីក្រឱ្យបានច្រើនជាមួយនឹងកំណើននោះ។ គេនៅមានសង្ឃឹមថា ប្រសិនបើអត្រាកំណើនរួមនៃផលិតផលក្នុងស្រុកបន្តនៅថេរ ហើយវិស័យកសិកម្មកើនឡើងក្នុងអត្រា ៤ % ក្នុងមួយឆ្នាំ ប្រទេសកម្ពុជាប្រហែលជាសម្រេច និងកើនហួសគោលដៅនៃការកាត់បន្ថយភាពក្រីក្រទៀតផង។ នេះមិនមែនមានន័យថា វិស័យឯទៀតអាចត្រូវបានបំភ្លេចចោលនោះទេ ដូចជាការលើកកម្ពស់វិស័យអប់រំ និងការបង្កើនសេវាកម្មសុខាភិបាល ព្រោះវាអាចជះឥទ្ធិពលដល់កំណើននៅតំបន់ ជនបទដែរ។

## ៣. តួនាទី និងយុទ្ធសាស្ត្រនៃក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍កសិកម្ម និងជនបទ

### ៣.១ ក្រសួងពាក់ព័ន្ធ

#### ៣.១.១ ក្រសួងមហាផ្ទៃ

៤៤. នៅឆ្នាំ១៩៩៣, យោងតាមអនុក្រឹត្យ[១៥] ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ក្រសួងមហាផ្ទៃបាន ចែងថា មាត្រា១ "**ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាស្ថាប័នចំណុះរាជរដ្ឋាភិបាល មានសមត្ថកិច្ចគ្រប់គ្រង ខេត្តក្រុងលើវិស័យរដ្ឋបាល គ្រប់គ្រងនគរបាលជាតិកម្ពុជា និងការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់ សាធារណៈនិងសុវត្ថិភាពជូនប្រជារាស្ត្រ**"។ **កិច្ចការចំបង** របស់ក្រសួងមហាផ្ទៃ គឺការខិតខំប្រឹងប្រែងអនុវត្ត នូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ពិសេសការអនុវត្តគោលនយោបាយកំណែទំរង់រដ្ឋបាលសាធារណៈ ដែលផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងសមត្ថភាពស្ថាប័នដែលជាគន្លឹះនៃការអភិវឌ្ឍនិងជាការយកចិត្តទុកដាក់ពិសេសថែមទៀត គឺការពង្រឹងការងារគ្រប់គ្រងមន្ត្រី តាមរយៈការបង្ហិត រដ្ឋបាលសាធារណៈបច្ចុប្បន្នឱ្យកាន់តែខិតជិតទៅរកប្រជាពលរដ្ឋ តាមរយៈគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ពិសេសការផ្ទេរអំណាចពីថ្នាក់លើទៅថ្នាក់ ក្រោមហើយកំណត់ច្បាស់នូវតួនាទី ភារកិច្ចសិទ្ធិអំណាចនិងការទទួលខុសត្រូវ របស់អាជ្ញាធរថ្នាក់ខេត្ត/ក្រុង ស្រុក/ខណ្ឌ ឃុំ/សង្កាត់[១៦]។

---

[១៣] ក្រសួងផែនការ, *របាយការគោលដៅអភិវឌ្ឍន៍សហវត្សរ៍ កម្ពុជា ២០០៣*,

[១៤] ធនាគារពិភពលោក, *កម្ពុជា: ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេនៅឆ្នាំ ២០១៥? ឯកសារវាយតម្លៃភាពក្រីក្រឆ្នាំ ២០០៦*, ភ្នំពេញ ខែកុម្ភៈ ឆ្នាំ ២០០៦

[១៥] អនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។

[១៦] ក្នុងព្រះរាជពិធីលៀងសាយភោជន៍ នៅព្រះដំណាក់ជ័យមង្គល ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៦

### ៣.១.២ ក្រសួងអភិវឌ្ឍន៍ជនបទ

**៤៥.** នាឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវ **"ក្រសួងអភិវឌ្ឍន៍ជនបទ"** ដើម្បីរៀបចំនូវ គោលនយោបាយអភិវឌ្ឍន៍ជនបទ (មើលឧបសម្ព័ន្ធទី១ ស្តីពីកំរងច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធក្រសួងអភិវឌ្ឍន៍ជនបទ) សំរបសំរួលសហប្រតិបត្តិការ អនុវត្តតាមដាននិងវាយតម្លៃ កម្មវិធីនិងគំរោង អភិវឌ្ឍន៍ជនបទ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ ជំហរនៃរាជរដ្ឋាភិបាលស្តីពីការបង្កើត **ក្រសួងអភិវឌ្ឍន៍ជនបទ** គឺបង្ហាញឱ្យឃើញនូវឆន្ទៈនិងផ្តល់ជាសារៈសំខាន់ក្នុងការយកចិត្តទុកដាក់ទៅលើ **"ការលើកស្ទួយកំរិតជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រជនបទ"** ហើយបានចាត់ទុក ក្រសួងអភិវឌ្ឍន៍ជនបទ ជាក្រសួងអាទិភាពក្នុងចំណោមក្រសួង ៤ និងជាសេនាធិការ ដ៏មានសារៈសំខាន់ក្នុងការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំ ដ៏វាងវៃនៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។ យោងតាម ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ស្តីអំពីច្បាប់បង្កើត ក្រសួងអភិវឌ្ឍន៍ជនបទ ចែងក្នុងមាត្រា២ ថាៈ **ក្រសួងអភិវឌ្ឍន៍ជនបទ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា** និងយោងតាមអនុក្រឹត្យ ស្តីអំពីការរៀបចំនិងប្រព្រឹត្ត ទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ លេខ៧៨អនក្រ.បក ចុះថ្ងៃទី១ ធ្នូ ១៩៩៧ ជំពូក២ (និង លេខ៥១ អនក្រ.បក ចុះថ្ងៃទី២១ មិថុនា ២០០១) ស្តីពី បេសកកម្ម និងរចនាសម្ព័ន្ធបានចែងនៅ**មាត្រា២** ថាៈ **ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រង វិស័យអភិវឌ្ឍន៍ជនបទ នៃព្រះរាជាណាចក្រកម្ពុជា** ។

**៤៦.** ក្រសួងអភិវឌ្ឍន៍ជនបទជាសេនាធិការដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍គោលនយោបាយ កាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ ក្រសួងអភិវឌ្ឍន៍ជនបទ គឺជាក្រសួងគន្លឹះមានចរិត អនុវត្ត ការងារការផ្សារភ្ជាប់កម្មវិធីអភិវឌ្ឍន៍ជនបទរបស់រាជរដ្ឋាភិបាល ជាមួយស្រទាប់ ប្រជាពលរដ្ឋនៅមូលដ្ឋាន ទូទាំងប្រទេស និងភ្នាក់ងារម្ចាស់អំណោយអន្តរជាតិ ។ ក្រសួងអភិវឌ្ឍន៍ជនបទជាក្រសួងមួយ ក្នុងចំណោម ក្រសួងឯទៀតៗ ដែលត្រូវការសហប្រតិបត្តិការនិងទំនាក់ទំនង យ៉ាងជិត ស្និទ និងមានតម្លាភាព ជាមួយ បណ្តាម្ចាស់អំណោយ និងភ្នាក់ងារអន្តរជាតិនានាក្នុងប្រទេស ។

**៤៧.** ទិសដៅរបស់ **ក្រសួងអភិវឌ្ឍន៍ជនបទ** គឺ បង្កើនកំរិតជីវភាពនៅជនបទ និងឈានទៅការកាត់បន្ថយភាពក្រីក្រ នៅជនបទកម្ពុជា តាមរយៈការសំរបសំរួលការសហការ និងការអនុវត្តកម្មវិធី និងគំរោង អភិវឌ្ឍន៍ជនបទចំរុះមានជាអាទិ- ការងារស្តារសាងសង់ថែទាំផ្លូវជនបទ ការងារផ្គត់ផ្គង់ទឹកស្អាត សុខភាពជនបទនិងអនាម័យ ការអភិវឌ្ឍន៍សហគមន៍ និងឥណទាន ជនបទ និងការអភិវឌ្ឍន៍ជនជាតិដើមភាគតិចជាដើម ។ **ក្រសួងអភិវឌ្ឍន៍ជនបទ** ជាស្ថាប័នសំរបសំរួល ដែលមានភារៈកិច្ច ជំរុញការងារសំរួលការដឹកជញ្ជូននៅជនបទ ការផ្គត់ផ្គង់ទឹកស្អាត ការសំរួលសេវាឥណទានជនបទ ការជំរុញនានាឱ្យមានការគ្រប់គ្រងធនធានធម្មជាតិ និងលើកតំកើងការងារអភិឌ្ឍន៍សហគមន៍ តាមរយៈការអនុវត្តគោលនយោបាយ អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ក្នុងនេះ **ក្រសួងអភិវឌ្ឍន៍ជនបទ** ជាយន្តការស្នូល ដែលដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការសំរបសំរួលរាល់សកម្មភាពអភិវឌ្ឍន៍ជនបទរវាងដៃគូពាក់ព័ន្ធទាំងអស់ ។

### ៣.១.៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រង លើវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា[១៧] ។ វិស័យកសិកម្ម ជាវិស័យអាទិភាពដែលរាជរដ្ឋាភិបាលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ចតុកោណយុទ្ធសាស្ត្រ ទី១ គឺការលើកស្ទួយវិស័កសិកម្មដែលនៅក្នុងនោះមានមុំ ៤ ជាចំបង មុំទី១- ការលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម, ទី២- កំណែទំរង់ដីធ្លីនិងបោសសំអាតមីន។ ទី៣-កំណែទំរង់វិស័យនេសាទ និងជលផល, និងទី៤- កំណែទំរង់ព្រៃឈើ ។ តួនាទីនិងភារកិច្ចរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ មានដូចតទៅ :

- រៀបចំនិងដាក់ឱ្យដំណើរការនយោបាយអភិវឌ្ឍន៏វិស័យកសិកម្ម ក្នុងគោលបំណងកែលំអជីវភាពប្រជាពលរដ្ឋ
- ចូលរួមក្នុងការរៀបចំគោលនយោបាយកែទំរង់ និងប្រើប្រាស់ដីធ្លី
- តំរង់ទិស និងធ្វើផែនការអភិវឌ្ឍន៏វិស័យកសិកម្មគ្រប់ផ្នែក
- សំរបសំរួល តាមដាន និងវាយតំលៃ លើការអនុវត្តនយោបាយ និងសកម្មភាពអភិវឌ្ឍន៏កសិកម្ម
- តាមដានការវិវត្តនៃធនធានធម្មជាតិ របស់វិស័យកសិកម្ម និងសំរួលដល់ការធ្វើអាជីវកម្មធនធានធម្មជាតិ ទាំងនោះ ដើម្បីបំពេញតំរូវការរបស់ប្រទេសជាតិ និងគោរពលំនឹងអេកូឡូស៊ី
- កំណត់បទប្បញ្ញត្តិក្នុងការគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិរបស់វិស័យកសិកម្ម និងតាមដានការអនុវត្ត
- វាយតំលៃនិងបណ្តុះបណ្តាលធនធានមនុស្ស សំរាប់ចូលរួមក្នុងការអភិវឌ្ឍន៏កសិកម្ម ដោយលើកកំពស់កំរិតយល់ដឹងបច្ចេកទេស និងបង្កលក្ខណៈប្រើប្រាស់ធនធាននេះឱ្យមានប្រសិទ្ធភាព
- ផ្តល់ការគាំទ្រនិងណែណាំបច្ចេកទេស ជាចាំបាច់ដល់កសិករ ដើម្បីកែលំអផលិតកម្ម និងផលិតភាពកសិកម្ម
- កំណត់គោលការណ៏និងតាមដានការអនុវត្ត លើកកំពស់ និងកែលំអដំណើរការប្រព្រឹត្តទៅរបស់អង្គការវិជ្ជាជីវៈសមាគមនានាដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម
- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ច ក្នុងវិស័យកសិកម្មគ្រប់ផ្នែក
- ណែនាំការងារអភិវឌ្ឍន៏ដី និងការកែលំអគុណភាពដី និងប្រើប្រាស់ដីកសិកម្ម ពូជរុក្ខជាតិ ពូជសត្វ ជីគីមី និងថ្នាំកសិកម្មឱ្យបានសមស្របទៅតាមលក្ខណៈភូមិសាស្ត្រ អាកាសធាតុ របស់តំបន់ ដើម្បីធានាបានទិន្នផលខ្ពស់ និងរក្សាតុល្យភាពបរិស្ថានធម្មជាតិ
- ធ្វើសហការជាតិ និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មគ្រប់ផ្នែក
- ចូលរួមក្នុងការជំរុញ និងលើកកំពស់ ការវិនិយោគ ការនាំចេញផលិតផលកសិកម្ម និងម្ហូបអាហារ
- ចូលរួមអនុវត្តការងារពាក់ព័ន្ធ នឹងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង
- ចូលរួមកសាងគោលនយោបាយថ្លៃ និងរកទីផ្សារសំរាប់ផលិតផលកសិកម្ម
- ប្រមូលថវិកាបង់ចូលរដ្ឋ ឬសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការប្រមូលចូលរដ្ឋ

---

[១៧] អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ៣.១.៤ ក្រសួងធនធានទឹក និងឧតុនិយម

**៤៩.** គោលនយោបាយរួមរបស់ក្រសួងធនធានទឹកនិងឧតុនិយម គឺ "ការគ្រប់គ្រងនឹងអភិវឌ្ឍធនធានទឹក ឱ្យមានប្រសិទ្ធិភាព និរន្តរភាព និងមានសមធម៌ ដើម្បីធានាបាននូវប្រព័ន្ធអេកូឡូស៊ី និងការកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីទឹក ដូចជាគ្រោះជំនន់ និងគ្រោះរាំងស្ងួត ដែលធ្វើឱ្យបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិសាធារណៈ" ។

**៥០.** គោលនយោបាយរួមរបស់ក្រសួងធនធានទឹកនិងឧតុនិយម គឺ *"ការគ្រប់គ្រងនឹងអភិវឌ្ឍធនធានទឹក ឱ្យមានប្រសិទ្ធិភាព និរន្តរភាព និងមានសមធម៌ ដើម្បីធានាបាននូវប្រព័ន្ធអេកូឡូស៊ី និងការកាត់បន្ថយផលប៉ះពាល់បណ្តាលមកពីទឹក ដូចជាគ្រោះជំនន់ និងគ្រោះរាំងស្ងួត ដែលធ្វើឱ្យបាត់បង់អាយុជីវិត និងទ្រព្យសម្បត្តិ សាធារណៈ"* ។ ក្រសួងធនធានទឹក និង ឧតុនិយម បានកំណត់គោលដៅសំខាន់ៗ ជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹករួមមាន :

- ការគ្រប់គ្រងធនធានទឹក និង ការអភិវឌ្ឍ
- ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត
- ការគ្រប់គ្រងព័ត៌មានធនធានទឹក
- ការជំរុញរៀបចំច្បាប់-បញ្ញត្តិ និងនិរន្តភាពនៃទឹក
- ការកែលំអ ការគ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍធនធានមនុស្ស

**៥១.** ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍ ត្រូវផ្តោតការយកចិត្តទុកដាក់លើ : **(ក)** ការធានាឱ្យបានទាំងប្រមាណ ទឹកគ្រប់គ្រាន់ និងគុណភាពទឹកសមស្របសំរាប់បំពេញតំរូវការឱ្យបានពេញមួយឆ្នាំដល់គ្រប់វិស័យ ព្រមទាំងថែរក្សាឱ្យបាននូវប្រព័ន្ធអេកូឡូស៊ីនៃទឹក, **(ខ)** ការគ្រប់គ្រងឱ្យបាននូវលំហូរទឹកជំនន់ និងបង្កើនសមត្ថភាពទប់ស្កាត់ និងទឹកជំនន់, **(គ)** ការគ្រប់គ្រងទឹកសំរាប់សំរាប់កសិកម្មតាមរយៈការបង្កើន ការកសាងប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក និងប្រព័ន្ធដោះទឹកសមស្រប, **(ឃ)** ការរក្សាធនធានទឹកកុំឱ្យមានភាពកខ្វក់ ដើម្បីទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី ជាពិសេសសំរាប់មច្ឆជាតិ ។

**៥២.** សកម្មភាពជាអាទិភាពលើការអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹក សំរាប់ឆ្នាំបន្តទៅខាងមុខនេះមានដូចខាងក្រោម :

- ធ្វើការត្រួតពិនិត្យ វាយតំលៃជាប្រចាំនូវស្ថានភាពធនធានទឹកលើដី និងក្រោមដីរៀងរាល់ឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការកំណត់ទិសដៅ និងដាក់ផែនការជាបន្តបន្ទាប់
- រៀបចំអនុក្រិត្យ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងទឹក
- ជួសជុល និងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក ប្រឡាយទឹក លូទឹក ប្រព័ន្ធដោះទឹក ប្រឡាយនាំដីល្បាប់ ទំនប់ការពារទឹកប្រៃ និងស្ថានីយបូមទឹកដើម្បីរក្សានិរន្តរភាពនៃការស្រោចស្រព សំរាប់ជំរុញការងារបង្កបង្កើនផលឱ្យបានពីរ ទៅបីដងក្នុងមួយឆ្នាំ
- បង្កើនការប្រើប្រាស់ធនធានទឹកក្រោមដី នៅតំបន់ដែលខ្សត់ទឹកលើដីឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព

- ជំរុញការគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រតាមប្រព័ន្ធវិមជ្ឈការ ដែលប្រជាជនធ្វើជាម្ចាស់ ដើម្បីដោះស្រាយទឹកសំរាប់បង្កបង្កើនផលផង ព្រមទាំងជួយសំរួលដល់ការធ្វើដំណើររបស់ប្រជាជន និងការអនុវត្តវារីវប្បកម្មផង
- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការគ្រប់គ្រងធនធានទឹក ដល់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអង្គការជាតិ និងអង្គការអន្តរជាតិ
- ប្រមូលផ្តុំចងក្រងទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធដល់ការអភិវឌ្ឍវិស័យធនធានទឹកនៅកម្ពុជា
- ជំរុញ និងលើកទឹកចិត្តដល់ការការពារ កែលំអ និងរក្សាស្ទឹង ព្រែក បឹងបួធម្មជាតិដើម្បីបំរើផលប្រយោជន៍រួម
- ពង្រឹងនិងពង្រីកបន្ថែម នូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីចូលរួមក្នុងការគ្រប់គ្រងទឹក បែងចែកទឹក និងថែរក្សាប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរក្សាបាននូវនិរន្តរភាព
- ជំរុញការវិនិយោគវិស័យឯកជនលើការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក ដែលពាក់ព័ន្ធការគ្រប់គ្រងទឹកសំរាប់កសិកម្ម
- ត្រៀមអន្តរាគមន៍ដើម្បីសង្គ្រោះស្រូវនៅតំបន់ដែលជួបប្រទះនូវភាពរាំងស្ងួត
- ជំរុញការគ្រប់គ្រងអាងទន្លេ និងការបែងចែកទឹកឱ្យបានសមស្រប និងមានប្រសិទ្ធភាព
- រៀបចំដំឡើង និងកែលំអរប្រព័ន្ធព្យាករណ៍ឧតុនិយម-ជលសាស្ត្រ ដើម្បីកាត់បន្ថយគ្រោះមហន្តរាយពីធម្មជាតិ ឈានទៅអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា ព្រមទាំងផ្តល់ព័ត៌មានស្តីពីអាកាសធាតុ និងជលសាស្ត្រឱ្យបានទាន់ពេលវេលាជូនដល់សាធារណជន
- ជំរុញការតាមដាន និងត្រួតពិនិត្យក្រុមហ៊ុនធ្វើអាជីវកម្មខ្សាច់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

### ៣.១.៥ ក្រសួងសុខាភិបាល

**៥៣. បេសកកម្មរបស់** ក្រសួងសុខាភិបាលជាស្ថាប័នរាជរដ្ឋាភិបាលនាំមុខគេ ទទួលខុសត្រូវដឹកនាំនិងគ្រប់គ្រងសេវាសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា[១៨]។ យោងតាមអនុក្រឹត្យលេខ ៦៧ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២២ ខែតុលាឆ្នាំ១៩៩៧ ត្រូវបានតែងតាំង ក្រសួងសុខាភិបាល ជាក្រសួងរបស់រាជរដ្ឋាភិបាល។ ក្រសួងសុខាភិបាល ទទួលខុសត្រូវរាល់កិច្ចការទាក់ទងនឹងវិស័យសុខាភិបាល រួមមានអភិវឌ្ឍន៏គំរោងយុទ្ធសាស្ត្រអនុវត្តន៏ និងវាយតំលៃសេវាសុខភាពសាធារណៈក្នុងប្រទេសកម្ពុជា។ ដើម្បីផ្តល់សេវាសុខភាពដែលមានប្រសិទ្ធិភាព និងជោគជ័យដល់ប្រជារាស្ត្រ ក្រសួងសុខាភិបាលបានរៀបចំអង្គការលេខ នៅទីស្តីការក្រសួង និង បែងចែកតួនាទី នឹងភារកិច្ចនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ យោងតាមអនុក្រឹត្យខាងលើអង្គការលេខរបស់ក្រសួងសុខាភិបាល ត្រូវបានរៀបចំអោយមានតួនាទី និងភារកិច្ចយ៉ាងច្បាស់លាស់គ្រប់ថ្នាក់។ អគ្គនាយកដ្ឋានចំនួនបីស្ថិតក្រោមរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល គឺ : អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន។ អគ្គនាយកដ្ឋាននីមួយៗគ្រប់គ្រងនាយកដ្ឋាន និង ការិយាល័យនានា ព្រមទាំងទទួលខុសត្រូវដែលបានចាត់ចែងដោយក្រសួងសុខាភិបាល។

[18] Source: www.moh.gov.kh

### ៣.១.៦ ក្រសួងបរិស្ថាន

**៥៤.** ក្រសួងបរិស្ថានមានតួនាទី និងភារកិច្ចទទួលខុសត្រូវគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ ប្រកបដោយនិរន្តរភាពក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ លើកកំពស់គុណភាពបរិស្ថាន ដោយគ្មានការបំពុលតាមរយៈកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ។ គោលដៅចំបងក្នុងការគ្រប់គ្រងធនធានធម្មជាតិ គឺដើម្បីធានាការអភិរក្ស និងការប្រើប្រាស់ ធនធានធម្មជាតិ និងជីវៈចំរុះ ប្រកបដោយនិរន្តរភាពដែលមានវិសាលភាពធំធេង និងផ្អែកលើមូលដ្ឋាន គតិយុត្តិក្រសួងបរិស្ថាន មានច្បាប់គោល គឺ "ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ" ដែលបានរដ្ឋសភាអនុម័តនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រមទាំងច្បាប់ពាក់ព័ន្ធមួយចំនួនទៀត ដូចជា ច្បាប់ភូមិបាល ច្បាប់ព្រៃឈើ ច្បាប់ជលផល ច្បាប់សំណង់ ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ជាតិ និងអនុក្រឹត្យមួយចំនួនទៀត និងមាន ប្រភពទិន្នន័យមូលដ្ឋានសំរាប់គាំទ្រដល់សកម្មភាពការងារច្បាស់លាស់។ សហគមន៍តំបន់ការពារធម្មជាតិ ដែលបានបង្កើតឡើងបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងចូលរួមការពារតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព ។

### ៣.១.៧ ក្រសួងសាធារណការនិងដឹកជញ្ជូន

**៥៥.** ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន និងដំណើរការអនុវត្តទីមុខងាររបស់ខ្លួន តាមរយៈអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។ អនុលោមតាមមាត្រា២ នៃព្រះរាជក្រមនេះ ក្រសួងសាធារណការនិងដឹកជញ្ជូន មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើ វិស័យសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងសាធារណការនិងដឹកជញ្ជូន បានខិតខំយ៉ាងសកម្ម ដើម្បី ស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ជាអាទិ ផ្លូវ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ អាកាសយានដ្ឋាន និងកំពង់ចំលង ឱ្យក្លាយជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដែលងាយស្រួល មានសុវត្ថិភាព និងមានសមត្ថភាពខ្ពស់ អាចដឹកជញ្ជូនទំនិញក្នុងបរិមាណច្រើនឆាប់រហ័ស និងមានតំលៃទាប ដោយតភ្ជាប់ ប្រទាក់ក្រឡាវាងទីក្រុង ទីប្រជុំជន តំបន់ជនបទដាច់ស្រយាល នៅទូទាំងប្រទេស និងតភ្ជាប់ជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ និងពិភពលោក សំដៅ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋកម្ពុជា បានឆាប់រហ័ស

## ៣.២ ស្ថាប័នពាក់ព័ន្ធ

**៥៦.** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវធ្វើការសហការឱ្យបានជិតស្និតជាមួយស្ថាប័នរបស់រាជរដ្ឋាភិបាលនានាដែលបានបង្កើតឡើងសំរាប់ដឹកនាំគ្រប់គ្រងកំណែទំរង់នានាដែលជាអាទិភាពនៃជ្រុងចតុកោណនីមួយៗ នៃយុទ្ធសាស្ត្រចតុកោណ។

### ៣.២.១ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា

**៥៧.** គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា "គ.ជ.នា." មានភារកិច្ចសំរាប់បម្រើរាជរដ្ឋាភិបាលក្នុងការងារសំរបសំរួល និងគៀងគរប្រភពធនធានដើម្បីការអភិវឌ្ឍន៍ប្រទេស ។

- ធ្វើជាចំណុចប្រមូលផ្តុំ និងជា **"ច្រកចេញចូលតែមួយ"** ក្នុងការទាក់ទងរវាងរដ្ឋាភិបាលជាមួយ នឹងប្រទេសអង្គការអន្តរជាតិនិងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាអ្នកផ្តល់ជំនួយដល់កម្ពុជានិងធ្វើជាចំណុចប្រមូលផ្តុំនិងជា "**ច្រកចេញចូលតែមួយ**" ក្នុងការទាក់ទងរវាងស្ថាប័ននានានៃរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួល ការទទួលជំនួយ និង ឬ ការបែងចែកជំនួយ
- រៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង និងសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំរបស់រដ្ឋាភិបាលក្នុងការអនុវឌ្ឍន៍ព្រមទាំងពង្រឹងភាពជាដៃគូជាមួយសហគមន៍អ្នកផ្តល់ជំនួយ
- គៀងគរ និងវិភាជន៍ជំនួយបរទេស សំរាប់អនុវត្តន៍គោលដៅអទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការអនុវឌ្ឍន៍តាមវិស័យ
- ដឹកនាំកិច្ចការសុខដុមកម្ម នៃការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនជំនួយបរទេស
- ផ្តល់ការកំទ្រផ្នែកបច្ចេកទេសដល់គណៈកម្មធិការសំរបសំរួលរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលជាយន្តការសំរាប់ពិភាក្សាកម្រិតគោលនយោបាយ និងផ្តល់ការគាំទ្រនានាសំរាប់ពង្រឹងយន្តការរបស់ក្រុមការងារបច្ចេកទេសចម្រុះ
- រួមជាមួយក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីរៀបចាំទស្សនាទានជាយុទ្ធសាស្ត្រសំរាប់និតិសម្បទានិងអភិវឌ្ឍន៍ប្រទេស និងដើម្បីលើកឡើងនូវលំដាប់អទិភាពនៃតំរូវការរបស់ប្រទេសជាតិ ក្នុងពេលបច្ចុប្បន្នជាបន្ទាន់ និងសំរាប់រយៈពេលខ្លី មធ្យម និងវែង ។ កម្មវិធីនេះមានលក្ខណៈជាប្រព័ន្ធរលូនប្រទាក់ក្រឡា និងស៊ី សង្វាក់គ្នា
- ចូលរួមរៀបចំផែនការសេដ្ឋកិច្ច សង្គមកិច្ច និងផែនការតាមផ្នែកសំរាប់អភិវឌ្ឍន៍កម្ពុជា
- គ្រប់គ្រងកិច្ចការវិនិនយោគសាធារណៈ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង និងស្ថាប័នទាំងឡាយដែលមានការពាក់ព័ន្ធ ។ ការងារនេះពាក់ព័ន្ធទៅនិងការសម្របសម្រួល និងការតំរង់ទិស ក្នុងការបែងចែក និងការប្រើប្រាស់ធន់ធាននៅក្នុងប្រទេស ដើម្បីកិច្ចការស្តារ និងអភិវឌ្ឍន៍កម្ពុជា
- តាមការប្រគល់សិទ្ធ ពីនាយករដ្ឋមន្ត្រី ចុះហត្ថលេខាតាងនាមរាជរដ្ឋាភិបាល ជាមួយនិងអ្នកផ្តល់ ជំនួយទ្វេភាគី ពហុ ភាគី និង/ឬ អង្គការអន្តជាតិនានា ដើម្បីទទួលជំនួយ និង /ឬការបែងចែកជំនួយ ។
- ដឹកនាំការងារក្នុងការរៀបចំឯកសារចាំបាច់នានា សំរាប់កិច្ចប្រជុំអន្តរជាតិសំរាប់ការកសាងប្រទេសកម្ពុជាឡើងវិញដូចជា **"ក្រុមពិគ្រោះយោបល់សម្រាប់កម្ពុជា"** ជាដើមដោយសហាកលារជាមួយក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ។
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល ដើម្បីរាជរដ្ឋាភិបាលពិនិត្យនិងលើកឡើង នូងវិធានការចាំបាច់សំរាប់កែលំអ និងតំរងទិសការងារនីតិសម្បទា និងការអភិវឌ្ឍន៍ ។

### ៣.២.២ ក្រុមប្រឹក្សាជាតិកំណែទំរង់រដ្ឋបាល

**៥៨.** ក្រុមប្រឹក្សានេះ មានភារកិច្ចនិងតួនាទីផ្តួចផ្តើមគំនិត សំរបសំរួល ជំរុញ និងឃ្លាំមើលការអនុវត្ត ទាំងផ្នែកបច្ចេកទេស និងបទពិសោធន៍ ដើម្បីឱ្យគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ អនុវត្តទៅបានប្រកបដោយជោគជ័យ ។

### ៣.២.៣ គណៈកម្មាធិការជាតិសំរបសំរួលការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**៥៩.** គណៈកម្មការនេះ មានកាតព្វកិច្ចទទួលខុសត្រូវជារួម ដើម្បីធានាការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាច្បាប់អង្គការ និងមានយន្តការគាំទ្រ សំរបសំរួល និងធ្វើការជាមួយក្រសួងស្ថាប័ន និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនានា សំដៅ ឈានទៅសំរេចទិសដៅរួមនៃការកសាង ជំរុញ និង និរន្តរភាពនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

### ៣.២.៤ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**៦០.** ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ហៅកាត់ថា "កបស" គឺជាស្ថាប័នខួរក្បាលខាងគោលនយោបាយសង្គម-សេដ្ឋកិច្ច សំរាប់ប្រមុខរាជរដ្ឋាភិបាល នៅអមទីស្តីការគណៈរដ្ឋមន្ត្រី ។ កបស មានមុខងារ និងភារកិច្ចដូចតទៅ :

- ពិនិត្យ និងរៀបចំឯកសារវិភាគ ស្រាវជ្រាវ និងសុន្ទរកថាសំខាន់ៗ ព្រមទាំងលើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយដែលមានចរិតជាចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទំរង់ និងអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ជូនប្រមុខ រាជរដ្ឋាភិបាល
- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព និងសង្គតិភាពនៃគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុងវិស័យនានា និងផ្តល់យោបល់ ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សំរាប់អនុវត្តឱ្យបានរលូននូវគោលនយោបាយ និងយុទ្ធសាស្ត្រផែនការប្រាំឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ
- ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអ ការគ្រប់គ្រងសង្គមកិច្ច-សេដ្ឋកិច្ច និងពង្រឹងអភិបាលកិច្ច ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច
- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាននិងបូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តផែនការប្រាំឆ្នាំ និងកម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីតំរង់ទិស និងបង្កើនល្បឿនអនុវត្តផែនការ និងកម្មវិធីទាំងនោះ
- ធ្វើជាសេនាធិការ ជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និងបូកសរុបការអនុវត្តការងារកំណែទំរង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់
- បូកសរុប និងធ្វើរបាយការណ៍សង្ខេប ជូនប្រមុខរាជរដ្ឋាភិបាលជ្រាប អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលដំណើរការនយោបាយ សេដ្ឋកិច្ចជាតិឱ្យស្របទៅតាមនិន្នាការវិវត្តន៍នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ
- បំពេញការងារផ្សេងទៀត តាមការបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ។

## ៤. បញ្ហាប្រឈមមុខ និងអនុសាសន៍

### ៤.១ បញ្ហាប្រឈម

**៦១.** ក្នុងគោលនយោបាយសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានសម្រេចបន្តជម្រុញអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដោយផ្តោតអាទិភាពទៅលើវិស័យធំៗ ចំនួន ១០ ដែលក្នុងនោះ ការស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវបានគ្របដណ្តប់ដោយប្រយោលទៅលើគ្រប់អាទិភាព ហើយរំលេចយ៉ាងច្បាស់នៅក្នុងអាទិភាពចំនួន ៤ រួមមាន កសិកម្ម ទឹក និងប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ ដូចដែលបានបង្ហាញខាងលើ ក្រសួង និងស្ថាប័ន ពាក់ព័ន្ធនានាទៅនឹងវិស័យស្តារ

និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំទិសដៅ បេសកកម្ម និងតួនាទីយ៉ាងច្បាស់លាស់ឆ្ពោះទៅកាន់គោលដៅរួមគ្នាមួយ ។ ប៉ុន្តែ គេត្រូវចាប់អារម្មណ៍ជាបន្ថែមទៀត ថាតើអ្វីខ្លះដែលអាចជាបញ្ហាប្រឈម នៅក្នុងការអភិវឌ្ឍន៍ចម្រុះនេះ ។

**៦២.** បញ្ហាប្រឈមចំបងទី ១ គឺស្ដែងឡើងពីធម្មជាតិនៃវិស័យ ។ មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនៅតូចចង្អៀត ដែលពឹងផ្អែកជាសំខាន់លើសសរទ្រូងបួន គឺវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម ។ វិស័យ ២ ដំបូង ជាវិស័យដែលមានខ្វះភាពឯករាជ្យ ដែលងាយរងនូវហានិភ័យពីខាងក្រៅ ។ វិស័យកសិកម្ម ដែលមានប្រមាណ ៣០ % នៃផលិតផលសរុបក្នុងស្រុក និងជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង ៦០ % មិនទាន់ប្រើអស់នូវសក្ដានុពលនៅឡើយ ។ ការប្រមូលផ្ដុំដីធ្លី និងចំនួនពលរដ្ឋដែលគ្មានដី មាននិន្នាការកើនឡើង ដែលជាការដាក់នូវបញ្ហាប្រឈមចំពោះសមធម៌ និងប្រសិទ្ធិភាពក្នុងការប្រើប្រាស់ដីធ្លី ។ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងបញ្ញត្តិ ការរំលោភដីរដ្ឋ ការកាប់រានទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិទៅធ្វើជាកម្មសិទ្ធិឯកជន និងការកាប់ឈើដោយខុសច្បាប់ នៅតែមានជាអន្លើៗ ។ ទន្ទឹមនឹងនេះ ភាពក្រីក្រ និងបាតុភូតចំណាកស្រុកទៅរានដីថ្មីល្មើសនឹងច្បាប់អនុញ្ញាត បានធ្វើអោយធនធានធម្មជាតិរងសម្ពាធនៃការបំផ្លាញ ។ ក្នុងបរិបទនៃការអភិវឌ្ឍន៍កសិកម្ម ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងការពិសោធន៍លើនវានុវត្តបច្ចេកវិទ្យាកសិកម្ម រវាងការអភិរក្ស និងអភិវឌ្ឍសេដ្ឋកិច្ច ។

**៦៣.** ផ្សារភ្ជាប់ជាមួយនឹងបញ្ហាធម្មជាតិនៃវិស័យខាងលើ គេសង្កេតឃើញថាបញ្ហាមួយទៀតដែលកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន គឺមានទំនាក់ទំនងនឹងការស្ដារនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ។ នៅពេលដែលរាជរដ្ឋាភិបាលបានបញ្ចប់ស្ទើរតែទាំងស្រុងនូវការស្ដារ និងកសាងឡើងវិញនូវបណ្ដាញផ្លូវជាតិទូទាំងប្រទេសរួចមក បញ្ហាប្រឈមរបស់កម្ពុជាគឺការធានាសុវត្ថិភាពចរាចរណ៍ **(សុវត្ថិភាពចរាចរណ៍ជនបទ ក្នុងបរិបទនៃការស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ)** ជាពិសេសការធានាជួសជុល ការថែទាំខួប និងជាប្រចាំនូវផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ ឱ្យបានជាប្រព័ន្ធ និងមានចីរភាព ។ ប្រព័ន្ធធារាសាស្ត្រ មិនទាន់អភិវឌ្ឍន៍គ្រប់គ្រាន់តាមតម្រូវការ និងមិនទាន់បានប្រើប្រាស់ឱ្យអស់សក្ដានុពលនៅឡើយ ដែលតម្រូវឱ្យមានយន្តការបង្កើនប្រសិទ្ធភាពគ្រប់គ្រង និងវិនិយោគបន្ថែម ។ សេវាកម្មថែទាំសុខភាព និងអនាម័យជនបទ រួមទាំងការផ្គត់ផ្គង់ទឹកស្អាតជនបទ សម្រេចបានក្នុងកម្រិតទាបនៅឡើយ បើធៀបនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។ ហិរញ្ញប្បទាន ការគ្រប់គ្រង និងបច្ចេកវិទ្យា កំពុងស្ថិតនៅជាបញ្ហាប្រឈមដ៏ស្រួចស្រាវ សម្រាប់ការអភិវឌ្ឍន៍វិស័យឯកជនជនបទ រួមមានសហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា ។ បញ្ហាប្រឈមប្រភេទនេះ អាចត្រូវបានចាត់ទុកថាជាបញ្ហាប្រឈមផ្នែកសេវាកម្ម និងរូបវ័ន្ត ។

**៦៤.** ក្នុងកិច្ចខិតខំដោះស្រាយសម្របសម្រួលនឹងបញ្ហាប្រឈមទាំងនេះ គេត្រូវងាកមកពិនិត្យបន្ថែមទៀត លើក្រុមគោលដៅនៃបញ្ហា ។ ដោយសារការទទួលបាននូវកម្រិតអប់រំតិចតួច អំពើហឹង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស គឺជាកត្តាដែលធ្វើឱ្យស្ត្រីមិនអាចប្រើប្រាស់អស់នូវសក្ដានុពលរបស់ខ្លួន ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ។ កិច្ចការពារសុវត្ថិភាពសង្គម ជាពិសេសសម្រាប់ពលករ និងជនក្រីក្រ នៅមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ ។ ការផលិត និងការជួញដូរគ្រឿងញៀន និងបញ្ហាអសីលធម៌សង្គម បានក្លាយជាបញ្ហាសង្គមមួយ ដែលអាចប៉ះពាល់ដល់សុខុមាលភាពយុវជន ទាំងនៅពេលបច្ចុប្បន្ន និងទាំងនៅពេលអនាគត ។ កង្វះខាតអ្នកបច្ចេកទេស និងពលករជំនាញ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរបន្ថែមទៀត ដែលរារាំងកិច្ចខិតខំពន្លឿនការអភិវឌ្ឍន៍សេដកិច្ច ទាំងនៅទីក្រុង និងទាំងនៅជនបទ ។

**៦៥.** ការប្រឈមទី ៣ ដែលស្ថិតនៅឆ្ងាយពីលទ្ធភាពទប់ទល់ដោយឯករាជ្យ គឺបាតុភូតបម្រែបម្រួលថ្មីៗនាពេលបច្ចុប្បន្ន។ បាតុភូតនៃការប្រែប្រួលអាកាសធាតុ អតុល្យភាពនៃសេដ្ឋកិច្ចពិភពលោក និងវិបត្តិហិរញ្ញវត្ថុ ដែលកើតមានក្នុងពេលថ្មីៗនេះ បណ្តាលឱ្យមានការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក រួមមានទាំងការកើនឡើងថ្លៃប្រេងឥន្ធនៈ និងស្បៀងអាហារ និងការចុះថ្លៃជាបន្តបន្ទាប់នៃប្រាក់ដុល្លារអាមេរិក បានដាក់មកលើសេដ្ឋកិច្ចកម្ពុជា នូវសម្ពាធអតិផរណាដ៏ធ្ងន់ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ការកើនឡើងនូវសេចក្តីត្រូវការក្នុងប្រទេស ដែលផ្សារភ្ជាប់ទៅនឹងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលកន្លងមក បានបង្កើនថែមទៀតនូវសម្ពាធអតិផរណានេះ។ ប្រការទាំងនេះ បង្កការគម្រាមលើទស្សនៈអនាគតនៃកំណើនសេដ្ឋកិច្ចកម្ពុជា។

**៦៦.** បញ្ហាប្រឈមមួយទៀត គឺស្តែងឡើងពីកិច្ចការសម្របសម្រួលថ្នាក់ស្ថាប័ន។ ក្រសួងសាមីនិមួយៗដែលអនុវត្តការងារពាក់ព័ន្ធនិងវិស័យកសិកម្មនិងជនបទ ច្រើនតែអនុវត្តឡើងតាមជំនាញរៀងៗខ្លួន និងមិនសូវមានការសម្របសម្រួល ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធឯទៀត។ ក្នុងបញ្ហាប្រឈមមួយចំនួនរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ[១៩] គឺមានកង្វះនូវភាពសម្របសម្រួលក្នុងផ្នែកទស្សនៈយុទ្ធសាស្ត្រ និងផែនការសកម្មច្រើន ដែលតែងតែជួបការប្រទាញប្រទង់ខ្លះ មិនទាន់អាចសម្របសម្រួលឱ្យឯកភាពគ្នាទាំងស្រុងបានជាកម្លាំងរួមមួយ ដើម្បីឆ្ពោះទៅរកការអនុវត្តន៏ជាក់ស្តែង ប្រកបដោយល្បឿនប្រសិទ្ធភាព ពោលគឺមិនអូសបន្លាយពេលវេលា។ កិច្ចសហការរវាងក្រសួងបរិស្ថាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការមួយចំនួន មិនទាន់បានលូតលាស់ មានភាពយឺតយ៉ាវ ឬគ្មានទំនាក់ទំនងពីបញ្ហាព័ត៌មាន និងទិន្នន័យ ព្រមទាំងតួនាទី និងភារកិច្ច ខ្លះអនុវត្ត មិនទាន់បានរលូន។ តាមរយៈការសិក្សាមួយបានលើកឡើងនៅក្នុងវេទិការអ្នកផ្តល់ជំនួយពិភពលោកសំរាប់អភិវឌ្ឍន៏ជនបទ[២០] សរសេរថា នៅកម្ពុជា មានស្ថាប័ននៃរាជរដ្ឋាភិបាលជាច្រើនទទួលអនុវត្តការងារអភិឌ្ឍន៏ជនបទ ប៉ុន្តែមិនមានស្ថាប័នណាមួយច្បាស់លាស់ជាអ្នកសម្របសម្រួលការងារវិស័យនេះទេ។ ជាទ្រឹស្តី ការសម្របសម្រួលការងារអភិវឌ្ឍន៏ជនបទនៅកម្ពុជា គឺជាតួនាទី និងជាភារកិច្ចរបស់ **ក្រសួងអភិវឌ្ឍន៏ជនបទ** ប៉ុន្តែកន្លងមកក្រសួងនេះ មិនទាន់អនុវត្តតាមតួនាទីរបស់ខ្លួន ហើយបច្ចុប្បន្ន គឺក្រសួងនេះកំពុងធ្វើតួនាទីខ្លួនត្រឹមតែជាភ្នាក់ងារអនុវត្តគំរោងតែប៉ុណ្ណោះ។

**៦៧.** នៅឆ្នាំ២០០៩ខាងមុខ រាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ នឹងអនុវត្តច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ដែលជាប្រភេទច្បាប់អង្គការ និងបានរៀបចំតាក់តែងឡើងស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងឆ្លើយតបតាមសភាពការណ៏ជាក់ស្តែងនៅកម្ពុជា សំដៅធានាឱ្យបាននូវនិរន្តភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។ ការងារនេះ ក៏មានការពាក់ព័ន្ធជាមួយការងារអភិវឌ្ឍន៏ជនបទផងដែរ។

## ៤.២ អនុសាសន៏

**៦៨.** ប្រឈមនិងតំរូវការឱ្យមានយន្តការស្ថាប័ន និងការសំរបសំរួល ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យមានវឌ្ឍនភាព និងការប្រែប្រួលជាគុណភាពក្នុងវិស័យទាំងមូល។ នៅដើមឆ្នាំ២០០៨នេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ក្នុងក្របខ័ណ្ឌនៃជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៏អាស៊ី ធ្វើការសិក្សាពិគ្រោះយោបល់មួយដើម្បីពិចារណាទៅលើតួនាទី ភារកិច្ចជា

---

[19] ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ — របាយការណ៏វឌ្ឍនភាព ឆ្នាំ២០០៤-២០០៧ ខែឧសភា-មិថុនា ឆ្នាំ២០០៨ ទំព័រ ២៣

[20] (Global Donors Platform for Rural Development - GDPRD i.e. ADB, AFD, BMZ, CIDA, DFID, EC, FAO, GTZ, IADB, IFAD, KFW, NRI, OECD, SDC Swiss, SIDA. USAID, WFP, World Bank)

អ្នកសំរបសំរួលការងារវិស័យកសិកម្មនិងជនបទ។ ថ្នាក់ដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ទទួលស្គាល់នូវភាពចាំបាច់នៃការកំណត់តួនាទីនិងភារកិច្ចមានការតំរង់ទិសច្បាស់លាស់ អនុវត្តការងារឱ្យសកម្មនិងស៊ីជំរៅ ព្រមទាំងឆ្លើយតបឱ្យមានប្រសិទ្ធភាព ដែលត្រូវប្រឈមជាមួយនិងតួនាទីសំរបសំរួល និងលើកកំពស់នៃការអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

**៦៩.** ដូច្នេះជាអនុសាសន៍ ដើម្បីកែលំអ និងលើកកំពស់សមត្ថភាព តួនាទីនិងភារកិច្ច និងជំរុញក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលមានតួនាទី ជាគណៈបញ្ជាការឯកភាពមួយជំនួយឱ្យរាជរដ្ឋាភិបាលក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដោយសហការគ្នាយ៉ាងជិតស្និត និងធ្វើការសំរបសំរួលការងារ ជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន ដើម្បីអនុវត្តឱ្យស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាព ដោយជៀសវាងការជាន់តួនាទី និងភារកិច្ច ប៉ុន្តែត្រូវប្រែក្លាយទៅជាភ្នាក់ងារកត្តាលិករវិជ្ជមានដើម្បីបង្កើនថាមភាពប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ បំពេញបន្ថែមគ្នាទៅវិញទៅមក ដែលក្រសួងសាមីនិមួយៗ មិនអាចសំរេចបានតែម្នាក់ឯង និងដើម្បីឱ្យផ្លែផ្កានៃការអភិវឌ្ឍន៍ទាំងឡាយ បានដល់ប្រជាពលរដ្ឋ និងឈានទៅកាត់បន្ថយភាពក្រីក្រនៅទីជនបទជាបណ្តើរៗ ដែលរាជរដ្ឋាភិបាលបានកំណត់ទិសដៅរួចហើយ ។

## ៥. ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

### ៥.១ ពង្រាងអនុក្រឹត្យ

**៧0.** ក្រោយពេលទទួលបាននូវសុខសន្តិភាព ប្រទេសកម្ពុជាបានឈានដល់ដំណាក់កាលមួយដ៏សំខាន់បំផុត សម្រាប់ការអភិវឌ្ឍន៍។ ប្រភេទ និងវិសាលភាពការងារដែលត្រូវផ្តល់នៅជនបទ ជាពិសេសការងារកសិកម្ម ការងារអភិវឌ្ឍន៍ជនបទ ការងារហេដ្ឋារចនាសម្ព័ន្ធជនបទ មានការពាក់ព័ន្ធគ្នាជាមួយក្រសួងជំនាញមួយចំនួន។ នៅឆ្នាំ ១៩៩៥ រាជរដ្ឋាភិបានសំរេចបង្កើត **ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** តាមរយៈអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៩៥ ដែលមាននាយករដ្ឋមន្ត្រី ជាប្រធាន និងមានក្រសួង ៩ និងស្ថាប័នមួយចំនួនជាសមាជិក។ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨/១០៤ បានត្រាស់បង្គាប់ តែងតាំង **សម្តេច ហ៊ុន សែន** ជាប្រធាន ដោយមានអនុប្រធានម្នាក់ អគ្គលេខាធិការម្នាក់ និងអគ្គលេខាធិការរង ៣ន ាក់ ជាសមាសភាពរបស់ **ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្មនិងជនបទ** ហៅកាត់ថា **ក.ក.ជ.** និងជាភាសាអង់គ្លេសថា **Council for Agricultural and Rural Development (CARD)**។ យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ក.ក.ជ. បានធ្វើការកែសម្រួលសមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ចមួយចំនួន ដើម្បីឱ្យស្របទៅនឹងស្ថានភាពអភិវឌ្ឍន៍ និងតំរូវការជាក់ស្តែងនៅកម្ពុជា។ ការកែសម្រួលលើកទី១ តាមរយៈអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ លើកទី២ អនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងលើកទី៣ ក្នុងអនុក្រឹត្យលេខ ១៦៦ អនក្រ-បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ បានកែសម្រួលសមាសភាព រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់ **ក.ក.ជ** មានគណៈកម្មាធិការប្រតិបត្តិថ្មី សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានតួនាទី ជាគណៈបញ្ជាការឯកភាពមួយ ជំនួយឱ្យរាជរដ្ឋាភិបាល ក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធ និងធ្វើការសម្របសម្រួល

ត្រួតពិនិត្យ និងវាយតម្លៃ ការងារជាមួយបណ្ដាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ជាពិសេសជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ និងដឹកជញ្ជូន ដើម្បីអនុវត្តឱ្យស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសំរេច អំពីមធ្យោបាយ សម្ភារៈទុន និងការងារផ្សេងៗទៀតដែលជួយឱ្យសំរេចរាល់ភារកិច្ចដែលមានចែង

## ៥.២ គោលគំនិតទូទៅ

**៧១.** នាពេលបច្ចុប្បន្ននេះ បើធៀបគ្នាទៅនឹងកាលពីរយៈពេល ១០ ឆ្នាំមុននៅអំឡុងពេលនៃការបង្កើតក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទជាលើកដំបូង គេសង្កេតឃើញថាបរិយាកាស ៥ យ៉ាង ដែលហ៊ុមព័ទ្ធក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវបានប្រែប្រួលគួរអោយកត់សម្គាល់។ ទោះបីជាការអភិវឌ្ឍន៍កសិកម្មជាកត្តា ចាំបាច់មួយសម្រាប់បង្កើនកំណើនសេដ្ឋកិច្ច ហើយភាគច្រើនលើសលុបនៃប្រជាជននៅតែប្រកបរបរកសិកម្ម ក៏វិភាគទាននៃវិស័យនេះនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកំពុងមានការថយចុះ។ ដូច្នេះការអភិវឌ្ឍន៍ជនបទត្រូវបានកែប្រែទិសដៅមករកវិស័យផ្សេងៗទៀត ដែលមិនមែនកសិកម្ម។ ជីវភាពប្រជាជននៅតំបន់ជនបទ មានការកែលំអឡើងយ៉ាងគួរអោយកត់សម្គាល់ ជាមួយគ្នានឹងការចូលរួមកាន់តែច្រើននៃវិស័យឯកជន។ ស្របពេលជាមួយគ្នានេះដែរ កំណែទម្រង់រដ្ឋបាល ពិសេសលើវិស័យវិមជ្ឈការកំពុងតែធ្វើដំណើរការជាបណ្ដើរៗ ដែលសកម្មភាពនេះពុំបានកើតមានទេកាលពី ១០ ឆ្នាំមុន។ ក្នុងគោលបំណងនៃការកាត់បន្ថយភាពក្រីក្រ ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានក្លាយខ្លួនទៅជាសហប្រធាននៃវេទិកាមួយចំនួន ដែលក្នុងនោះរួមមានផ្នែកសន្តិសុខស្បៀង។ ជាចុងក្រោយបើធៀបកាលពី ១០ ឆ្នាំមុន គេសង្កេតឃើញថានាពេល បច្ចុប្បន្ននេះយុទ្ធសាស្ត្រថ្នាក់ជាតិមួយចំនួន ត្រូវបានពិភាក្សាតាក់តែងរួចជាស្រេច ដែលក្នុងនោះក្រុមការងារបច្ចេកទេសមួយចំនួនត្រូវបានបង្កើតឡើង។

**៧២.** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ បានចង្អុលទិសឱ្យគ្រប់ក្រសួងស្ថាប័ន បន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និងម្មត់ចត់បំផុត នូវកំណែទំរង់ទាំងឡាយដែលបានដាក់ចេញកន្លងមកនេះ ឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀត មានជាអាទិ៍ :

- កំណែទំរង់វិមជ្ឈការ និងសហវិមជ្ឈការ ដឹកនាំដោយក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិ
- កំណែទំរង់រដ្ឋបាលសាធារណៈ ដឹកនាំដោយទីស្ដីការគណៈរដ្ឋមន្ត្រី
- កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដោយឡែកការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានតួនាទីមិនអាចខ្វះបានរបស់ ក.ក.ជ

## ៥.៣ សមាសភាព និងរចនាសម្ព័ន្ធ របស់ ក.ក.ជ

**៧៣.** ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ គឺជាស្ថាប័នសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃ សមាសភាព និងរចនាសម្ព័ន្ធដើម្បីបំពេញការងារ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍។ សមាសភាពក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានដូចតទៅ :

- ឥស្សរជនជាន់ខ្ពស់មួយរូប ប្រធាន
- ឥស្សរជនមួយ ឬ ច្រើនរូប អនុប្រធាន

- អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងផែនការ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងកិច្ចការនារី សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន សមាជិក
- រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ឬ តំណាង សមាជិក
- ប្រធានធនាគារអភិវឌ្ឍន៍ជនបទ ឬ តំណាង សមាជិក
- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ តំណាង សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សមាជិក
- អគ្គលេខាធិការអាជ្ញាធរអាងទន្លេសាប សមាជិក
- មេបញ្ជាការ បញ្ជាការដ្ឋានវិស្វកម្ម នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

**៧៤.** ការកែសម្រួលតួនាទីភារកិច្ចជាថ្មី ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវបានជំរុញអោយទៅជាគណៈបញ្ជាការឯកភាពមួយ ដើម្បីជាសេនាធិការអោយរាជរដ្ឋាភិបាលក្នុងការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយក្នុងនោះត្រូវសហការយ៉ាងជិតស្និទ្ធ និងធ្វើការសំរបសំរួលការងារជាមួយ បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ។

**៧៥.** គណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានសមាសភាពដូចតទៅ

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្តម | **យឹម** | **ឆៃលី** | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម | **តាវ** | **សេងហួរ** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធានទី១ |
| ៣- | ឯកឧត្តម | **ងី** | **ច័ន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានទី២ |
| ៤- | ឯកឧត្តម | **លី** | **ប៊ុនម៉េង** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធានទី៣ |
| ៥- | ឯកឧត្តម | **រ័ត្ន** | **វិរៈ** | អគ្គលេខាធិការ | |
| ៦- | ឯកឧត្តម | **ប្លុង** | **សារ៉េត** | អគ្គលេខាធិការរង | |
| ៧- | ឯកឧត្តម | **ស្រ៊ុន** | **ដារិទ្ធ** | អគ្គលេខាធិការរង | |
| ៨- | ឯកឧត្តម | **សុខ** | **ស៊ីឡូ** | អគ្គលេខាធិការរង | |
| ៩- | ឯកឧត្តម | **ឡៅ** | **សុខារម្យ** | អគ្គលេខាធិការរង | |
| ១០- | ឯកឧត្តម | **ហៃ** | **សេង** | អគ្គលេខាធិការរង | |
| ១១- | ឯកឧត្តម | **ជ័យ** | **សាវឿន** | អគ្គលេខាធិការរង | |
| ១២- | ឯកឧត្តម | **តូច** | **ប៊ុនហួរ** | អគ្គលេខាធិការរង | |
| ១៣- | ឯកឧត្តម | **សាន** | **វឌ្ឍនា** | អគ្គលេខាធិការរង | |
| ១៤- | លោកជំទាវ | **ណី** | **សុឃឹម** | អគ្គលេខាធិការរង | |
| ១៥- | ឯកឧត្តម | **ហុង** | **រដ្ឋាវុធ** | អគ្គលេខាធិការរង | |
| ១៦- | ឯកឧត្តម | **ណាំ** | **លីណាល់** | អគ្គលេខាធិការរង | |
| ១៧- | លោកស្រី | **គង់** | **វណ្ណា** | ប្រធាននាយកដ្ឋានរដ្ឋបាល ផ្គត់ផ្គង់និងហិរញ្ញវត្ថុ | |
| ១៨- | លោក | **ភាន់** | **ឫទ្ធី** | ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ | |
| ២០- | លោក | **សុខ** | **សំអាង** | ប្រធាននាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | |
| ២១- | លោក | **ជូ** | **ប៊ុនហៀង** | ប្រធាននាយកដ្ឋានកសិកម្ម និងបរិស្ថាន | |
| ២២- | លោក | **ឈឹម** | **សុខា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនបទ | |
| ២៣- | លោក | **ហុង** | **លាងហេង** | ប្រធាននាយកដ្ឋានធនធានទឹក | |
| ២៤- | លោក | **ផល** | **សុជាតិ** | ប្រធាននាយកដ្ឋានសាធារណការ | |



រូបថតទី១: សមាសភាពថ្នាក់ដឹកនាំនៃ គ.ក.ជ ចូលរួមក្នុងកិច្ចប្រជុំផ្ទៃក្នុង

## ៥.៤ តួនាទី និងភារកិច្ចរបស់ គ.ក.ជ

**៧៦.** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានធ្វើការវាយតំលៃអំពីស្ថានភាពរួមកន្លងមក និងកំណត់ទិសដៅជាយុទ្ធសាស្ត្រសំរាប់ការងារបន្ត។ ស្ថានភាពការវិវត្តទៅមុខនៅកម្ពុជា ក៏ដូចជានៅក្នុងពិភពលោក តម្រូវឱ្យយើងពិចារណាថែមទៀត ដើម្បីពង្រឹងយន្តការអនុវត្តការងារឱ្យមានប្រសិទ្ធិភាព សមស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ ក្នុងសកម្មភាពកែទំរង់ ដើម្បីពង្រឹងគុណភាពអភិបាលកិច្ចល្អ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកំរិតខ្ពស់ ដែលជាកត្តាចាំបាច់បំផុត សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវបំពេញភារកិច្ចដូចខាងក្រោម :

- ក.ក.ជ ត្រូវពំពេញតួនាទីជាគណៈបញ្ជាការឯកភាពមួយ ជំនួយការឱ្យរាជរដ្ឋាភិបាលក្នុងកិច្ចសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តន៍គម្រោងនានាពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយសហការគ្នា យ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ឱ្យមានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសម្រេចអំពីមធ្យោបាយ សម្ភារ: ទុន និងការងារផ្សេងៗទៀត
- ក.ក.ជ កំណត់ទិសដៅអាទិភាពលើកម្មវិធីនយោបាយ និងបញ្ហាអន្តរវិស័យ ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ឱ្យសមស្រមតាមគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ក.ក.ជ មានភារកិច្ចកំណត់នូវបញ្ហាអន្តរវិស័យ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជម្រុញការដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងកិច្ចពិភាក្សាគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ជាពិសេស ពិនិត្យផ្តល់យោបល់ លើសំណើដែលបានស្នើសុំពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ ក្រោមជាតិ ដៃគូ អភិវឌ្ឍន៍ សង្គមស៊ីវិល

និងវិស័យឯកជន ដែលពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ហើយរាយការណ៍ និងសុំយោបល់ ពីរាជរដ្ឋាភិបាល

## ៥.៥ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃ ក.ក.ជ

**៧៧.** អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មានតួនាទីជាសេនាធិការឱ្យ ក.ក.ជ និងមានភារកិច្ចដូចខាងក្រោម ៖

- ទទួលបន្ទុកចាត់ការទូទៅ គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់ ក.ក.ជ ប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
- សម្របសម្រួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ វិស័យកសិកម្ម និងជនបទ ដោយសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ជាពិសេសជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផ្តល់ប្រឹក្សា តាមដាន ត្រួតពិនិត្យ និងចូលរួមវាយតម្លៃការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។
- ទទួលបន្ទុកដឹកនាំសម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- សហការ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ លើវិស័យសេដ្ឋកិច្ច វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ការវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍន៍បច្ចេកវិទ្យានានា ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម ។
- ប្រមូល វិភាគ ធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ជម្រុញ និងបណ្តុះបណ្តាលជំនាញ ដើម្បីលើកកម្ពស់សមត្ថភាព និងការយល់ដឹងដល់បុគ្គលិក មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន និងអ្នកពាក់ព័ន្ធ

**៧៨.** អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មាននាយកដ្ឋានជំនាញ ចំនួន៧ គឺ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ នាយកដ្ឋានកសិកម្ម និងបរិស្ថាន នាយកដ្ឋានអភិវឌ្ឍន៍ជនបទ នាយកដ្ឋានធនធានទឹក និងនាយកដ្ឋានសាធារណការ និងមាន ២៧ ការិយាល័យ ។



រូបថតទី២: សមាសភាពអ្នកចូលរួម ក្នុងកិច្ចប្រជុំផ្ទៃក្នុងនៃ គ.ក.ជ

## ៥.៦ តួនាទី និងភារកិច្ចរបស់នាយកដ្ឋាន

### ៥.៦.១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**៧៩.** ក្នុងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាន ៥ ការិយាល័យ នៅក្រោមឱវាទ គឺ : ការិយាល័យរដ្ឋបាល និងពិធីការ ការិយាល័យបុគ្គលិក និងបៀវត្សរ៍ពលកម្ម ការិយាល័យគណនេយ្យ ការិយាល័យហិរញ្ញកិច្ច និងការិយាល័យផ្គត់ផ្គង់ និងសម្ភារៈ។ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវលើការងាររដ្ឋបាល និងប្រតិបត្តិការការងារ ហិរញ្ញវត្ថុ របស់គ.ក.ជ។

### ៥.៦.២ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ

**៨០.** នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ មាន ៤ ការិយាល័យនៅក្រោមឱវាទ គឺ ការិយាល័យសម្របសម្រួលគោលនយោបាយ ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ ការិយាល័យស្ថិតិ និងផែនការមូលដ្ឋានចំរុះ និងការិយាល័យសហប្រតិបត្តិការអន្តរជាតិ។ នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចៈ

- សម្របសម្រួល សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍នានា រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងផែនការរបស់អគ្គលេខាធិការដ្ឋាននៃ គ.ក.ជ និងបណ្តុះបណ្តាលធនធានមនុស្សនូវជំនាញបច្ចេកទេសនានា
- ក្នុងការសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ គ្រប់គ្រងប្រព័ន្ធទិន្នន័យ និងស្ថិតិ ដើម្បីបង្កើតផែនការមូលដ្ឋានចម្រុះ ព្រមទាំងបញ្ចូលទិន្នន័យ និងស្ថិតិទាំងនោះទៅក្នុងផែនទីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាមូលដ្ឋាននៃការវិភាគ និងរៀបចំផែនការអភិវឌ្ឍន៍
- ចូលរួមសហការផ្តល់យោបល់ណែនាំ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃក្នុងការអនុវត្តន៍ផែនការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ។

### ៥.៦.៣ នាយកដ្ឋាន សុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**៨១.** ក្នុងនាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មាន ៥ ការិយាល័យនៅក្រោមឱវាទ គឺ ការិយាល័យសុខាភិបាល និងសុខភាពសហគមន៍ ការិយាល័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការិយាល័យគ្រប់គ្រងពត៌មាន ការិយាល័យសម្របសម្រួលវិស័យសុខាភិបាល និងកិច្ចការរដ្ឋបាល និងការិយាល័យត្រួតពិនិត្យ និងវាយតម្លៃវិស័យសុខាភិបាល។ នាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានភារកិច្ច :

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកំពស់វិស័យសុខាភិបាល សន្តិសុខស្បៀង រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងចូលរួមអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការលើកស្ទួយសុខុមាលភាពប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រ ស្ត្រី និងកុមារ
- ចូលរួមពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផលប៉ះពាល់នៃការអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងវិស័យសុខាភិបាល និងសន្តិសុខស្បៀង
- បណ្តុះបណ្តាលចំណេះដឹងលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន
- អភិវឌ្ឍ ថែទាំ និងធ្វើបច្ចុប្បន្នភាពវិបសាយរបស់ គ.ក.ជ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន

### ៥.៦.៤ នាយកដ្ឋាន កសិកម្ម និងបរិស្ថាន

**៨២.** ក្នុងនាយកដ្ឋានសុខាភិបាល កសិកម្ម និងបរិស្ថាន មាន ៤ ការិយាល័យនៅក្រោមឱវាទ គឺ ការិយាល័យកសិកម្ម និងផលិតកម្មសត្វ ការិយាល័យព្រៃឈើ និងជលផល ការិយាល័យគ្រប់គ្រងដីកសិកម្ម និងការិយាល័យបរិស្ថាន។ នាយកដ្ឋានកសិកម្ម និងបរិស្ថាន មានភារកិច្ច :

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានា ស្តីពីការ អភិវឌ្ឍន៍វិស័យកសិកម្ម និងការការពារបរិស្ថាន
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មាន អំពីស្ថានភាពកសិកម្ម និងបរិស្ថាន ដើម្បីសហការរៀបចំផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើការងារអភិវឌ្ឍន៍វិស័យកសិកម្ម និងបរិស្ថាន
- ចូលរួមពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីនានា ពាក់ព័ន្ធនឹងវិស័យកសិកម្ម សំដៅលើកកំពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម កំណែទម្រង់វិស័យនេសាទ និងជលផល កំណែទម្រង់ព្រៃឈើ និងកំណែទម្រង់ដីធ្លីកសិកម្ម
- ចូលរួមពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តន៍កម្មវិធីនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន ដើម្បីគ្រប់គ្រង ថែរក្សាការពារអភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព

### ៥.៦.៥ នាយកដ្ឋាន អភិវឌ្ឍន៍ជនបទ

**៨៣.** ក្នុងនាយកដ្ឋានអភិវឌ្ឍន៍ជនបទ មាន ៣ ការិយាល័យនៅក្រោមឱវាទ គឺ ការិយាល័យពលកម្មជនបទ និងចំណាកស្រុក ការិយាល័យយេនឌ័រ និងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចជនបទ និងការិយាល័យទឹកស្អាត និងអនាម័យជនបទ។ នាយកដ្ឋានអភិវឌ្ឍន៍ជនបទ មានភារកិច្ច :

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន មានដូចជា:
  - រៀបចំប្រព័ន្ធសុវត្ថិភាពសង្គម កាលានុវត្តភាពការងារ ការបញ្ជ្រាប យេនឌ័រទៅក្នុងការអភិវឌ្ឍន៍ និងសុវត្ថិភាពនៃការធ្វើចំណាកស្រុក
  - រៀបចំទិន្នន័យ ស្ថិតិ ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទ ដើម្បីរៀបចំផែនការចម្រុះថ្នាក់ជាតិ ក្រោមជាតិ និងផែនការយុទ្ធសាស្ត្រលើការងារអភិវឌ្ឍន៍ជនបទ
  - អនុវត្តន៍កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ សំដៅការពង្រឹងសមត្ថភាពនៅគ្រប់ថ្នាក់ ដើម្បីផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ព្រមទាំងសមត្ថភាពក្នុងការអនុវត្តន៍អភិបាលកិច្ចល្អ
  - រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងយន្តការអភិបាលកិច្ចល្អ ក្នុងសកម្មភាពអភិវឌ្ឍន៍ជនបទ និងការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ដើម្បីកែច្នៃផលិតផល សម្រាប់បំពេញតម្រូវការក្នុងស្រុក និងការនាំចេញ ដើម្បីធានានូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចនៅជនបទ
- ចូលរួមពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោង នានាពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍ជនបទ។

### ៥.៦.៦ នាយកដ្ឋាន ធនធានទឹក

**៨៤.** ក្នុងនាយកដ្ឋានធនធានទឹក មាន ៣ ការិយាល័យនៅក្រោមឱវាទ គឺការិយាល័យអភិវឌ្ឍន៍ និងតម្លៃទាំហេដ្ឋារចនាសម្ព័ន្ធ ការិយាល័យសម្របសម្រួល និងវាយតម្លៃធនធានទឹក ការិយាល័យអភិវឌ្ឍន៍ធនធានទឹក និងសហគមន៍ប្រើប្រាស់ទឹក។ នាយកដ្ឋានធនធានទឹក មានភារកិច្ច :

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍កសិករប្រើប្រាស់ទឹក និងវិស័យឯកជន លើការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងការគ្រប់គ្រងទឹកសំរាប់កសិកម្ម ដើម្បីលើកកំពស់ការអភិវឌ្ឍន៍វិស័យធនធានទឹកស្របតាមកម្មវិធី នយោបាយរបស់រាជរដ្ឋាភិបាល
- សហការសិក្សាស្រាវជ្រាវ និងស្វែងរកដៃគូអភិវឌ្ឍន៍ដើម្បីរៀបចំគម្រោងធារាសាស្ត្រជនបទ រួមមានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អាងស្តុកទឹក ប្រឡាយទឹក ប្រព័ន្ធដោះទឹក ប្រឡាយនាំដីល្បាប់ ទំនប់ការពារទឹកជំនន់ ទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីរក្សានិរន្តរភាពនៃការស្រោចស្រព
- សម្របសម្រួលត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការរៀបចំ និងការអនុវត្តន៍គោលនយោបាយជាតិស្តីពីការសាងសង់ ថែទាំ និងការគ្រប់គ្រងសំណង់ប្រព័ន្ធធារាសាស្ត្រ ស្របតាមគោលការណ៍ច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងវិស័យធនធានទឹក
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មាន អំពីស្ថានភាពធនធានទឹក ដើម្បីសហការរៀបចំផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើការងារអភិវឌ្ឍន៍វិស័យធនធានទឹក។

### ៥.៦.៧ នាយកដ្ឋានសាធារណៈការ

**៨៥.** ក្នុងនាយកដ្ឋានសាធារណៈការ មាន ៣ ការិយាល័យនៅក្រោមឱវាទ គឺ ការិយាល័យសំណង់ និងរចនាសម្ព័ន្ធសាធារណៈការជនបទ ការិយាល័យគមនាគមន៍ជនបទ ការិយាល័យសម្របសម្រួល និងវាយតម្លៃវិស័យសាធារៈការ។ នាយកដ្ឋានសាធារណៈការ មានភារកិច្ច :

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន លើការគ្រប់គ្រង ការស្តារ និងការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពហុប្រភេទ ការប្រើប្រាស់បណ្តាញគមនាគមន៍ជនបទ ការអភិវឌ្ឍន៍វិស័យសាធារណការ និងដឹកជញ្ជូន ដើម្បីលើកកំពស់ការអភិវឌ្ឍន៍វិស័យសាធារណការ និងគមនាគមន៍ជនបទ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សម្របសម្រួល តាមដាន និងវាយតម្លៃលើការរៀបចំ និងការអនុវត្តន៍គោលនយោបាយជាតិ ស្តីពីការសាងសង់ ថែទាំ និងការគ្រប់គ្រងសំណង់សាធារណការ ស្របតាមគោលការណ៍ច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងវិស័យសាធារណការ និងដឹកជញ្ជូន
- បន្តជម្រុញ និងលើកទឹកចិត្តឱ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក្រុង និងជនបទ
- សហការសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ព័ត៌មាន អំពីបទបញ្ញត្តិ បទដ្ឋានបច្ចេកទេស និងស្តង់ដារផ្សេងៗ ស្តីអំពីការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

## ៥.៧ សកម្មភាពជាបន្ត

**៨៦.** សកម្មភាពមួយចំនួនដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ត្រូវចាប់ផ្តើមជាបន្ទាន់ និងធ្វើឱ្យសម្រេចបានក្នុងរយៈពេលយ៉ាងយូរ៦ខែ ដែលត្រូវចាប់ពីពេលនេះ (វិច្ឆិកា២០០៨ - មេសា ២០០៩) ដើម្បីជម្រុញកំណែទម្រង់ក្រុមប្រឹក្សានេះ ដើរតួនាទីសមស្របតាមស្ថានភាពបច្ចុប្បន្ន មានជាអាទិ :

- **សកម្មភាពទី១-** (ថ្ងៃទី៦ ខែវិច្ឆិកា ២០០៨ មុនបុណ្យអុំទូក): ធ្វើការប្រជុំការងារជាមួយគ្រប់សមាសភាពនៃថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីរៀបចំផែនការការងារ និងសកម្មភាពដែលត្រូវអនុវត្តចំពោះមុខ (រយពេល ៦ខែ) លើទិសដៅកែលំអរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ច ដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នៅក្នុងបរិបទនៃការអភិវឌ្ឍន៍បច្ចុប្បន្ន។ ត្រៀមចងក្រងឯកសារជំនួយស្មារតី ដើម្បីធ្វើការពិភាក្សា
- **សកម្មភាពទី២-** (ដើមខែវិច្ឆិកា ២០០៨ មុនបុណ្យអុំទូក) ធ្វើការពិភាក្សាស៊ីជំរៅលើពង្រាងទស្សនទានដែលបានសិក្សារៀបចំដោយទីប្រឹក្សាក្រោមជំនួយបច្ចេកទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូនៃកម្មវិធីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- **សកម្មភាពទី៣-** (ចុងខែវិច្ឆិកា ២០០៨ ក្រោយបុណ្យអុំទូក) ធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធដែលជាសមាជិក ស្តីពីលទ្ធផល និងទិសដៅកែលំអរចនាសម្ព័ន្ធដឹកនាំក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- **សកម្មភាពទី៤-** (ចុងខែវិច្ឆិកា ២០០៨ ក្រោយបុណ្យអុំទូក) ធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសនានាដែលមានការពាក់ព័ន្ធជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- **សកម្មភាពទី៥-** (ដើមខែធ្នូ ២០០៨ មុនថ្ងៃទី១៥ មុនបុណ្យចូលឆ្នាំសាកល) ពង្រាងអនុក្រឹត្យ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ សមាសភាព តួនាទី ភារកិច្ច របស់ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍ វិស័យកសិកម្មនិងជនបទ
- **សកម្មភាពទី៦-** (ដើមខែ មករា ឆ្នាំ២០០៩) ប្រជុំពិភាក្សាឆ្លងលើពង្រាងអនុក្រឹត្យថ្មី របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- **សកម្មភាពទី៧-** (ខែកុម្ភៈ ឆ្នាំ២០០៩) សិក្ខាសាលាថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយពី រចនាសម្ព័ន្ធ សមាសភាព តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដល់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍
- **សកម្មភាពទី៨-** រៀបចំផែនការងារសំរាប់រយៈពេល៥ឆ្នាំ ២០០៩-២០១៣ (ខែមករា-មិនា ឆ្នាំ២០០៩)
- **សកម្មភាពទី៩-** គៀងគរធនធានសំរាប់អភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ឱ្យបានសមស្រប (ជាប្រចាំ)

## ៦. ការវិភាគទៅលើអតិក្រមនៃដំណើរការអគ្គលេខាធិការដ្ឋាននៃ ក.ក.៩

**៨៧.** ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ កំពុងស្ថិតក្នុងដំណាក់កាលរៀបចំយុទ្ធសាស្ត្រមួយដ៏ប្រសើរ ដោយបង្កើតអោយមានកម្មវិធីការងារជាក់លាក់មួយ ស្របពេលដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំ

រចនាសម្ព័ន្ធថ្មីឡើង ពីថ្នាក់នាយកដ្ឋាន រហូតដល់ថ្នាក់ការិយាល័យជំនាញ។ មុននឹងដាក់ចេញជាយុទ្ធសាស្ត្រសម្រាប់ស្ថាប័ន គេត្រូវពិចារណាលើគោលនយោបាយនៃស្ថាប័ននោះជាមុន ហើយលទ្ធផលនៃការរៀបចំយុទ្ធសាស្ត្រមួយដ៏ប្រសើរនោះ នឹងបង្កើតអោយមានជាកម្មវិធីការងារជាក់លាក់មួយឡើង។ ដូច្នេះ សំណួរស្ថិតនៅត្រង់ថា តើគេត្រូវធ្វើយ៉ាងណាដើម្បីអោយ ក.ក.ជ ក្លាយជាស្ថាប័នមួយដែលដឹកនាំអោយមានការផ្លាស់ប្តូរមួយ លើវិស័យអភិវឌ្ឍន៍កសិកម្ម និងជនបទ។ ក.ក.ជ គឺជាស្ថាប័នសម្របសម្រួលមួយ មានភារកិច្ចសំខាន់ៗចំនួន ៤ ដែលត្រូវបានចាត់ទុកជាចំនុចគន្លឹះ ក្នុងការរៀបចំឡើងជាយុទ្ធសាស្ត្រ រួមមាន:

- គាំទ្រអោយមាននូវការបង្កើតឡើងនូវនយោបាយ និងយុទ្ធសាស្ត្រដើម្បីបង្ហាញនូវគម្លាត និងបញ្ហាអន្តរវិស័យទាំងនោះ ដោយបកប្រែនូវចំណេះដឹងអោយទៅជាគោលបំណងដែលអាចមានសកម្មភាពបាន **(Policy Support)**
- គាំទ្រអោយមាននូវការប្រាស្រ័យទាក់ទង ដែលជួយអោយមានការកំណត់នូវគម្លាតបញ្ហាអន្តរវិស័យ និងអាទិភាពសម្រាប់ការអភិវឌ្ឍន៍កសិកម្ម និងជនបទ **(Partnership and Dialogue)** ពិសេសពិនិត្យផ្តល់យោបល់លើសំណើដែលបានស្នើសុំពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជនដែលពាក់ព័ន្ធការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ហើយរាយការណ៍ និងសុំយោបល់ពីរាជរដ្ឋាភិបាល
- ចូលរួមវិភាគទានក្នុងការវាយតម្លៃដំណើរការដែលឆ្ពោះទៅរកគោលបំណងថ្នាក់ជាតិ (យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ...) ដើម្បីធានាបម្លាស់ប្តូរទម្រង់នៃចំណេះដឹងប្រកបដោយប្រសិទ្ធិភាព អោយទៅជាលទ្ធផលនិងមានដំណើរការនៅមូលដ្ឋាន **(Monitoring and Evaluation)**
- បង្កើនភាពផ្សារភ្ជាប់ និងធានាអោយបាននូវរំហូរនៃពត៌មានទៅកាន់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ដោយបង្កើត ប្រមូល គ្រប់គ្រង និងចែកចាយជាថ្មីនូវចំណេះដឹង ទោះបីជាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ពុំមែនជាស្ថាប័នស្រាវជ្រាវមួយក៏ដោយ **(Information and Knowledge Management)**

## ៦.១ តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការទ្រទ្រង់នយោបាយ

**៨៨.** ក្នុងភារកិច្ចដំបូងជាស្ថាប័នដែលផ្តល់ការទ្រទ្រង់នយោបាយ ក.ក.ជ តាមរយៈនាយកដ្ឋានជំនាញនីមួយៗ នឹងសម្លឹងមើលទៅលើរចនាសម្ព័ន្ធទ្រទ្រង់នយោបាយ ពោលគឺចំនុចនៃការចាប់ផ្តើមគឺរចនាសម្ព័ន្ធដែលបានរៀបចំរួច។ ចំណែកចរន្តនៃការទ្រទ្រង់នយោបាយ គឺស្ថិតនៅលើហេដ្ឋារចនាសម្ព័ន្ធនៃការអភិវឌ្ឍន៍ យុទ្ធសាស្ត្រនិងនយោបាយ តាមរយៈក្រុមការងារបច្ចេកទេស ដែលមានការពាក់ព័ន្ធជាមួយនឹងការងារអភិវឌ្ឍន៍កសិកម្ម និងជនបទ។ ដូចដែលបានចែងនៅក្នុងតួនាទី និងភារកិច្ច នាយកដ្ឋាននីមួយៗនឹងបន្តនូវការធ្វើបច្ចុប្បន្នភាពទៅលើនយោបាយពាក់ព័ន្ធ អាទិភាព និងយុទ្ធសាស្ត្រនៅក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទទៅតាមប្រភេទជំនាញនៃនាយកដ្ឋាន តាមរយៈកិច្ចប្រាស្រ័យទាក់ទង ដែលកំពុងអនុវត្ត និងការផ្លោះប្តូរពត៌មានជាមួយក្រសួង ស្ថាប័នផ្តល់ជំនួយ សង្គមស៊ីវិល វិស័យឯកជន និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ បន្ថែមលើនេះ នាយកដ្ឋានជំនាញនីមួយៗនឹងត្រូវដើរតួនាទីជាសេនាធិការរបស់ ក.ក.ជ និងក្រុមការងារបច្ចេកទេស និងចូលរួមនៅក្នុងក្រុមការងារពាក់ព័ន្ធទាំងឡាយ ដែលបានបង្កើតឡើងជាផ្នែកមួយនៃការអភិវឌ្ឍន៍នយោបាយនិងយុទ្ធសាស្ត្រដែលផ្តួចផ្តើមឡើងដោយក្រសួង និងក្រុមការងារបច្ចេកទេសមួយចំនួន។

**៨៩.** យន្តការនៃការអនុវត្តតួនាទីជាអន្តរការីដែលផ្ដល់ការទ្រទ្រង់នយោបាយរបស់នាយកដ្ឋានជំនាញនីមួយៗ រួមមាន **១. ការធ្វើជាអ្នកតំណាងរបស់ ក.ក.ជ** នៅក្នុងការប្រឹក្សាពិគ្រោះ ពិនិត្យ និងការពិភាក្សានយោបាយនៅក្នុងអន្តរក្រសួងដែលពាក់ព័ន្ធ ដោយកំណត់នូវបញ្ហាអន្តរវិស័យដែលមានការពាក់ព័ន្ធជាមួយការអភិវឌ្ឍន៍កសិកម្មនិងជនបទ ពីការពិភាក្សានានា និងធានាថា បញ្ហាអន្តរវិស័យទាំងនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សានយោបាយ និងយុទ្ធសាស្ត្រខាងមុខទៀត **២. ចូលរួមកំណត់យុទ្ធសាស្ត្រអាទិភាព និងសូចនាករ** ពីឯកសារនយោបាយនានា ជាអាទិ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ ឬ ផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ ដែលស្ថិតនៅក្នុងដែនកំនត់នៃអណត្តិការងាររបស់ ក.ក.ជ។ បន្ថែមលើនេះទៀត នាយកដ្ឋាននីមួយៗនឹងចូលរួមជា **៣. ការផ្ដល់វិភាគទានទៅកាន់ការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** នៅថ្នាក់ក្រោមជាតិ ទោះក្នុងទ្រង់ទ្រាយសាកល្បង និងធានានូវការចូលរួមអោយបានគ្រប់គ្រាន់ និងភាពដែលអាចរកបាននៃធនធានសម្រាប់ទម្រង់ផ្សេងៗនៃការទ្រទ្រង់នយោបាយ និងការប្រាស្រ័យទាក់ទងលើការអភិវឌ្ឍន៍យុទ្ធសាស្ត្រ។

**៩០.** តាមរយៈការិយាល័យចំណុះ គ្រប់នាយកដ្ឋានទាំងអស់ត្រូវទទួលខុសត្រូវសម្រាប់ការចូលរួម ជាលក្ខណៈសកម្មឬអកម្ម នៅក្នុងការទ្រទ្រង់នយោបាយ តាមរយៈក្រុមការងារបច្ចេកទេស និងទៅតាមតម្រូវការនៃវិស័យជំនាញឬគោលនយោបាយ ដែលមាននៅក្នុងផែនការសកម្មភាព។ កម្រិតនៃភាពជាប់ទាក់ទងនៅក្នុងវិស័យនយោបាយនីមួយៗ ពុំត្រូវដូចគ្នាជាដាច់ខាតរហូតនោះទេ ពោលគឺ ក.ក.ជ អាចផ្ដល់នូវអាទិភាពសម្រាប់ភាពជាប់ទាក់ទងរបស់ខ្លួននៅក្នុងវិស័យខ្លះ ឬដើរតួនាទីជាអ្នកអង្កេតការនៅក្នុងវិស័យខ្លះផ្សេងទៀត។ សមត្ថភាព ធនធានមនុស្ស និងហិរញ្ញវត្ថុ ជាកត្តាកំនត់អភិក្រមទាំងនេះ។

## ៦.២ តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធនិងភាពជាដៃគូ

**៩១.** ជាច្រើនលើកច្រើនសា នៅក្នុងបទបរិយាយនៃតួនាទី និងភារកិច្ចនៃនាយកដ្ឋានជំនាញនីមួយៗ គេអាចសង្កេតឃើញនូវការប្រើពាក្យផ្ទួនគ្នាជាច្រើន ពីប្រភេទនៃដៃគូ និងស្ថាប័នពាក់ព័ន្ធជាមួយសកម្មភាព និងដំណើរប្រព្រឹត្តទៅនៃ ក.ក.ជ។ គេអាចសង្ខេបបាននូវចរន្តនៃការប្រាស្រ័យទាក់ទងនិងភាពជាដៃគូ ចំនួន ៤ រួមមាន **១. ស្ថាប័ននៃរាជរដ្ឋាភិបាល** សំដៅលើក្រសួងជំនាញ គណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សានិងអាជ្ញាធរអន្តរក្រសួងផ្សេងៗទៀត រួមមាន ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ឬក្រុមប្រឹក្សានយោបាយដីធ្លី ជាដើម ដែលយន្តការទំនាក់ទំនងជាមួយស្ថាប័នទាំងនេះ អាចធ្វើឡើងតាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមការងារបច្ចេកទេស ឬទំនាក់ទំនងដោយផ្ទាល់ **២. ដៃគូអភិវឌ្ឍន៍នានា** សំដៅលើដៃគូអភិវឌ្ឍន៍ជាលក្ខណៈទ្វេភាគី ឬពហុភាគី ក្នុងទម្រង់ជាតិ ឬអន្តរជាតិ ហើយដែលអាចធ្វើឡើងតាមរយៈទំនាក់ទំនងទ្វេភាគីដោយផ្ទាល់ តាមក្រុមការងារបច្ចេកទេស ឬតាមរយៈវេទិកានានា ពិសេសវេទិកានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **៣. សង្គមស៊ីវិល** សំដៅលើអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ សហព័ន្ធឬសមាគមនានា និង **៤. ស្ថាប័នឯកជន** ដែលសំដៅលើ ក្រុមឧស្សាហកម្ម និងអង្គការផ្សេងៗ។ នាពេលអនាគតឆាប់ៗខាងមុខនេះ ស្ថាប័នពាក់ព័ន្ធដ៏សំខាន់មួយទៀតសម្រាប់ ក.ក.ជ នឹងត្រូវបានប្រសូតឡើង ហើយដែលនឹងក្លាយទៅជាសសរស្ដម្ភនៃការអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នោះគឺ **៥. អាជ្ញាធរថ្នាក់ក្រោមជាតិ**។

**៩២.** ក្នុងការបំពេញតួនាទីនេះ នាយកដ្ឋានជំនាញនីមួយៗ នឹងត្រូវដើរតួនាទីឱ្យបានរលូន ក្នុងយន្តការប្រាស្រ័យទាក់ទងនយោបាយ និងធ្វើការសម្របសម្រួលនៅក្នុងទំនាក់ទំនងខ្សែទទឹង និងខ្សែបណ្តោយ ដោយរក្សាអោយបាននូវការប្រាស្រ័យទាក់ទងដែលកំពុងតែមានដំណើរការ នៅកម្រិតអន្តរក្រសួង និងរៀបចំជាប្រចាំនូវកិច្ចប្រជុំថ្នាក់អន្តរក្រសួង។ ការវាយតម្លៃលើទិសដៅនៃសកម្មភាពរបស់ស្ថាប័នទាំងនោះ ឆ្ពោះទៅកាន់អាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជារបៀបវារៈសំខាន់មួយនៃការស្ថាប័នភាពជាដៃគូ របស់ ក.ក.ជ ដែលក្នុងនោះសំដៅលើការសហការបង្កើត និងការផ្តល់នូវវេទិកាសម្រាប់ការត្រួតពិនិត្យការពិភាក្សាជាប្រចាំ ការផ្លាស់ប្តូរនូវបទពិសោធន៍ និងការទាញចេញនូវបទពិសោធន៍ដែលបាន។ នាយកដ្ឋានជំនាញនៃ ក.ក.ជ ក៏ត្រូវសហការក្នុងការបង្កើតនូវវេទិកា សម្រាប់កិច្ចពិភាក្សាថ្នាក់ក្រោមជាតិ ក្នុងការបង្កើតឡើងនូវជំនួបដែលមានសកម្មភាពមួយរវាងអង្គភាពថ្នាក់ក្រោមជាតិជាមួយសហគមន៍កសិកម្ម និងសម្របសម្រួលនូវ បទពិសោធន៍នៃកម្មវិធីនិងគម្រោងដែលទ្រទ្រង់ដោយរាជរដ្ឋាភិបាល ស្ថាប័នផ្តល់ជំនួយ សង្គមស៊ីវិល និងវិស័យឯកជន។

## ៦.៣ តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង

**៩៣.** តួនាទីនេះ មានសារៈសំខាន់ជាខ្លាំងសម្រាប់ដំណើរប្រព្រឹត្តនៃ ក.ក.ជ ក្នុងនាមជាអ្នកផ្តល់វិភាគទាន ដ៏មានប្រសិទ្ធិភាពចំពោះដំណើរការនៃការអភិវឌ្ឍន៍កសិកម្មនិងជនបទ។ ស្នូលនៃសកម្មភាពក្នុងការគ្រប់គ្រងពតិមាន និងចំណេះដឹង គឺការធ្វើឱ្យអាចរកបាននូវកម្រងចំណេះដឹងដែលកើនឡើងជាលំដាប់នៅក្នុងការអភិវឌ្ឍន៍ និងឧបត្ថម្ភនូវគំនិត និងសេវាកម្ម។ នាយកដ្ឋានជំនាញនីមួយៗ ត្រូវមានតួនាទីសម្របសម្រួល និងគ្រប់គ្រងនវានុវត្តន៍ និងការសិក្សាស្ថាប័ន ពិសេសធ្វើការជម្រុញនូវជំនាញពិសេស និង "ការប្រមូលផ្តុំនូវបញ្ញា" ពីគ្រប់ស្ថាប័នពាក់ព័ន្ធនៅក្នុងការងារអភិវឌ្ឍន៍កសិកម្មនិងជនបទ និងនៅទូទាំង ក.ក.ជ។ ភារកិច្ចបន្ទាប់ពីការប្រមូលផ្តុំ គឺការបង្កើនឡើងនូវចំណេះដឹងដែលអាចប្រើប្រាស់បានសាជាថ្មី និងដែលមានអត្ថន័យ និងធានាឱ្យបានថាមាតិកានៃចំណេះដឹងទាំងនេះអាចត្រូវបានបញ្ជូនតគ្នាបាន តាមរយៈចរន្តផ្សេងៗ។

**៩៤.** យន្តការនៃការគ្រប់គ្រងពតិមាន និងចំណេះដឹងរួមមាន **១. ប្រមូលចំណេះដឹង** តាមរយៈការចាប់ទាក់យកនូវពតិមានរូបសាស្ត្រ និងអេឡិកត្រូនិកពីគ្រប់ស្ថាប័នពាក់ព័ន្ធ **២. បង្កើនចំណេះដឹង** ដោយបង្កើតជាចំណេះដឹងតាមរយៈកិច្ចខិតខំរួមគ្នានៅក្នុងការធ្វើការស្រាវជ្រាវផ្សារភ្ជាប់នឹងសកម្មភាព វគ្គសិក្សា និងកម្មសិក្សាផ្សេងៗ **៣. គ្រប់គ្រងចំណេះដឹង** រួមមានការគ្រប់គ្រងការរក្សាពតិមាន ក្នុងបណ្ណាល័យ ឬលើវេបសាយ និងធានានូវការចូលទៅដល់ និងការប្រើប្រាស់បានជាបន្តទៅមុខនូវ ពតិមានទាំងនោះ **៤. ចែកចាយចំណេះដឹង** ដោយធានាឱ្យបានថា រាល់បណ្តុំមាតិកាផ្សេងៗអាចឈានទៅដល់អ្នកប្រើប្រាស់ដែលជាគោលដៅ ដោយផ្លូវផ្សេងៗគ្នា និងដែលអាចត្រួតពិនិត្យបាន។ ពតិមាន និងចំណេះដឹង អាចត្រូវបានចែកចាយដោយបែបបទ អកម្ម គឺតាមរយៈការបោះពុម្ពផ្សាយ និងការភ្ជាប់ទៅកាន់វេបសាយ ជាកន្លែងដែលអ្នកប្រើប្រាស់អាចទទួលពតិមានបានដោយខ្លួនគេផ្ទាល់ ឬដោយបែបបទសកម្ម តាមរយៈការបង្កើតប្រព័ន្ធគណៈកម្មការត្រួតពិនិត្យ តាមរយៈការបោះពុម្ព ផ្សាយលើអត្ថបទដែលជាគោលដៅ ឬការរៀបចំនូវវគ្គសិក្សាលើប្រធានបទពិសេសជាក់លាក់។

## ៦.៤ តួនាទីនៃនាយកដ្ឋានជំនាញ ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ

**៩៥.** ភារកិច្ចនៃដំណើរការនៃការត្រួតពិនិត្យ និងចំនុចរាំងស្ទះនានាលើការងារអភិវឌ្ឍន៍កសិកម្មនិងជនបទ មានភាពទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការទ្រទ្រង់ផ្នែកប្រាស្រ័យទាក់ទង ការគ្រប់គ្រងពតិមាន និងការទ្រទ្រង់នយោបាយ។ នាយកដ្ឋានជំនាញដែលមានការពាក់ព័ន្ធនឹងការងារនេះ ត្រូវចូលរួមនិងធ្វើរបាយការណ៍លើសកម្មភាពក្រុមការងារបច្ចេកទេស ឬក្រុមការងារដ៏ទៃទៀត ដែលត្រូវបានបង្កើតឡើងក្នុងទម្រង់ជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងនយោបាយ ដែលផ្តួចផ្តើមបង្កើតឡើងដោយក្រសួងជំនាញ និងស្ថាប័នពាក់ព័ន្ធ។ កម្មវត្ថុសំខាន់នៃការវាយតម្លៃ គឺការត្រួតពិនិត្យមើលលើសង្គតភាពនៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្របខណ្ឌនៃវិមជ្ឈការនិងវិសហមជ្ឈការនៅកម្រិតថ្នាក់ជាតិនិងក្រោមជាតិ។

**៩៦.** យន្តការក្នុងការបំពេញតួនាទីជាស្ថាប័នត្រួតពិនិត្យ និងវាយតម្លៃនេះ រួមមាន **១. ចូលរួម និងធ្វើរបាយការណ៍** លើសកម្មភាពនៃក្រុមការងារបច្ចេកទេស និងក្រុមការងារពាក់ព័ន្ធដ៏ទៃទៀត **២. ចូលរួមនៅក្នុងបេសកកម្មសិក្សា និងវិនិច្ឆ័យវិភាគ** ទៅតាមការកំណត់ប្រតិទិនដែលត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសនីមួយៗ **៣. ការចូលរួមធ្វើការរៀបចំក្នុងកិច្ចសហប្រតិបត្តិការ** ជាមួយក្រសួង ឬ ស្ថាប័នពាក់ព័ន្ធ ក្នុងការបង្កើតឡើងនូវ គម្រោងឬ កម្មវិធី និងត្រួតពិនិត្យបេសកកម្ម និង **៤. ជម្រុញឬផ្តល់ការគាំទ្រ** ទៅដល់ភាពជាម្ចាស់កម្មសិទ្ធិនៃកម្ពុជា ទៅលើគម្រោងនិងគំនិតផ្តួចផ្តើមទាំងឡាយ ដែលត្រូវបានទ្រទ្រង់ដោយភាគីបរទេស។

## ៧ ការវាយតម្លៃលើបញ្ហាប្រឈម និងនិតិវិធីនៃដំណើរការសកម្មភាពខ្សែទនឹង

**៩៧.** ដូចដែលបានលើកឡើងជាអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ គេអាចវិភាគបានថា ក.ក.ជ នឹងត្រូវដើរតួនាទីជាប៉ូលមួយ ជាមួយប៉ូលបីទៀតរួមមានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្នុងការជម្រុញស្ថេរភាព និងពន្លឿនល្បឿនអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ ការរៀបចំរចនាសម្ព័ន្ធថ្មី និងកំណែសម្រួលលើតួនាទីនិងភារកិច្ចនៃស្ថាប័ន ក.ក.ជ ត្រូវបានធ្វើឡើងក្នុងគោលបំណងបង្កើនភាពរលូនក្នុងការអនុវត្តសកម្មភាព។ ជាមួយគ្នានេះ សមាហរណកម្មនៃភារកិច្ច ចំណេះដឹង និងធនធានមនុស្សថ្មីទៅក្នុងប្រព័ន្ធរឹងមាំដែលមានស្រាប់ នឹងត្រូវកើតមានឡើង។ ប្រការនេះអាចជាលក្ខណៈគុណសម្បត្តិមួយ ប៉ុន្តែវាក៏អាចជា**បញ្ហាប្រឈមទី ១ គឺការកំណត់រកចំនុចចាប់ផ្តើម និងយន្តការនៃសមាហរណកម្ម**។

**៩៨.** ការងារ សម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃ ជាកិច្ចការសំខាន់មួយ ហើយដែលមិនមែនជាការងារងាយស្រួលក្នុងការអនុវត្តឡើយ។ ក្រសួងនិងស្ថាប័នដែលមានតួនាទីពាក់ព័ន្ធនឹងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តែងមានការការពារសិទ្ធិស្វ័យត និងផលប្រយោជន៍ផ្ទាល់របស់គេ ហើយអាជ្ញាកិច្ចរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ពុំបានពឹងផ្អែកលើសិទ្ធិគ្រប់ដណ្តប់ និងការគ្រប់គ្រងលើធនធានឡើយ។ ក្នុងតួនាទីជាអន្តរការីសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃលើការងារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក.ក.ជ នឹងត្រូវដើរតួនាទីជាស្ថាប័នបំផុសអោយការយល់ឃើញលើបញ្ហាជាអន្តរវិស័យ ប៉ុន្តែពុំមែនជាស្ថាប័នដែលបង្កើតបញ្ហាជាអន្តរវិស័យនោះទេ។ គេអាចលើកជាសំណួរថា តើយន្តការអ្វីដែលអាចលើកឡើងដើម្បីកំណត់បញ្ហាទាំងនោះ ព្រមទាំងអាទិភាពរបស់វា។ ដូច្នេះ **បញ្ហាប្រឈមទី ២** នៃនាយកដ្ឋានជំនាញនានាចំណុះអោយអគ្គលេខា

ធិការដ្ឋាននៃ ក.ក.ជ គឺ**ការកំណត់ការពិភាក្សាស្វែងរកនូវបញ្ហាដែលកើតឡើងជាលក្ខណៈអន្តរវិស័យ និងដោយមានការចូលរួមចម្រុះ**។

**៩៩.** ប្រសិនបើគេធ្វើការពិនិត្យទៅលើតួនាទី និងភារកិច្ចនៃអគ្គលេខាធិការដ្ឋាននៃ ក.ក.ជ ក៏ដូចជាតួនាទី និងភារកិច្ចនៃនាយកដ្ឋានទាំងលាយចំណុះឱ្យ ក.ក.ជ គេសង្កេតឃើញស្ថានភាពដឹកនាំការងារតាមបែបអភិក្រមពីលើចុះក្រោម យ៉ាងរឹងមាំ ហើយដែលប្រព័ន្ធដឹកនាំបែបនេះ គឺកើតមាននៅស្ទើរគ្រប់ស្ថាប័នរដ្ឋ។ បែបផែននៃការប្រគល់តួនាទី និងភារកិច្ចតាមប្រព័ន្ធនេះ អនុញ្ញាតអោយនាយកដ្ឋាននីមួយៗ អាចដើរតួនាទីជាសសរស្តម្ភនៃអគ្គលេខាធិការដ្ឋាន ហើយបំពេញការងារជាលក្ខណៈឯករាជ្យ ដែលមិនទាក់ទងជាមួយនាយកដ្ឋានដទៃ។ ពិតណាស់ដែល ក.ក.ជ ជាស្ថាប័នមួយដែលមានកម្មវត្ថុ និងគោលបំណងធំទូលាយ ហើយទាមទារនូវយន្តការមួយ ដែលប្រព័ន្ធការងារទាំងអស់ត្រូវមានកិច្ចសម្របសម្រួលខ្ពស់ ហើយតម្រូវឱ្យទំនាក់ទំនងក្នុងភាពជាដៃគូ មិនត្រឹមតែរវាង ក.ក.ជ ជាមួយមជ្ឈដ្ឋានស្ថាប័នខាងក្រៅប៉ុណ្ណោះទេ តែថែមទាំងរវាងអង្គភាពនាយកដ្ឋានផ្ទៃក្នុងអគ្គលេខាធិការដ្ឋាននៃ ក.ក.ជ ត្រូវប្រព្រឹត្តទៅឱ្យបានរលូនថែមទៀតផង។ គេអាចលើកឡើងជាសំណួរថា តើ ក.ក.ជ អាចបំពេញតួនាទីជាស្ថាប័នទ្រទ្រង់ សម្របសម្រួល ដែលនាំអោយមាននវានុវត្តមួយបានដោយជោគជ័យដែរឬទេ ប្រសិនបើយន្តការមួយដែលកំណត់ឱ្យឃើញពីលទ្ធភាពនាំទៅរកនវានុវត្តនោះនៅពុំទាន់ផ្តល់និយមន័យនៅឡើយ។ ដូច្នេះ **បញ្ហាប្រឈមទី ៣ គឺការកំណត់រកឱ្យឃើញ នូវយន្តការសម្របសម្រួលផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន**។

**១០០.** បន្ថែមលើនេះទៀត ក្នុងបរិបទនៃនវានុវត្តស្ថាប័ន ក.ក.ជ ដែលកំពុងតែចាប់ដំណើរការ គេសង្កេតឃើញថានាយកដ្ឋានជំនាញនីមួយៗ មានបទដ្ឋានក្នុងការរៀបចំការិយាល័យចំណុះ ក្នុងសណ្ឋានខុសៗគ្នា។ តួនាទីគ្រប់គ្រងស្ថិតិមូលដ្ឋាននៃធនធានបុគ្គលិក ត្រូវបានប្រគល់ទៅដល់នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចំណែកតួនាទីក្នុងការបណ្តុះបណ្តាលធនធានមនុស្ស នឹងក្លាយទៅជាបន្ទុកនៃនាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ។ តួនាទីក្នុងការសម្របសម្រួលលើស្ថាប័នជំនាញ ត្រូវបានប្រគល់ទៅដល់ការិយាល័យដោយឡែកមួយ នៅក្នុងនាយកដ្ឋាន រួមមាននាយកដ្ឋានសុខាភិបាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងនាយកដ្ឋានសាធារណការ ចំណែកនាយកដ្ឋានកសិកម្ម និងបរិស្ថាន នាយកដ្ឋានអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានធនធានទឹក បានបញ្ជ្រាបតួនាទីសម្របសម្រួល និងវាយតម្លៃនេះ ទៅក្នុងគ្រប់ការិយាល័យជំនាញទាំងអស់។ ដូចក្នុងចំណុចដំបូងដែរ វាអាចនឹងក្លាយជាគុណសម្បត្តិមួយក្នុងការដកស្រង់បទពិសោធន៍ ប៉ុន្តែវាអាចជា**បញ្ហាប្រឈមទី ៤ ក្នុងការអនុវត្តការងារក្នុងឯកសណ្ឋានភាពមួយ នៅក្នុងអគ្គលេខាធិការដ្ឋាន ក.ក.ជ**។

**១០១.** បញ្ហាប្រឈមទាំងអម្បាលម៉ានខាងលើ នឹងត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃការពិភាក្សាជាបន្តទៀត។ ទោះជាយ៉ាងណា គេអាចកត់សម្គាល់ឃើញថា បញ្ហាប្រឈមទាំងនេះស្ថិតនៅជាប់ពាក់ព័ន្ធនឹងបញ្ហារួមមាន គឺការសម្របសម្រួល។ ជាអនុសាសន៍ក្នុងការដោះស្រាយលើបញ្ហានេះ ជាជំហានដំបូងគេគួរកំណត់ឱ្យបានជាក់លាក់ នូវមុខព្រួញ ឬសកម្មភាពគ្រឹះនៃនាយកដ្ឋាននីមួយៗ។ សកម្មភាពគ្រឹះទាំងនេះ នឹងផ្តល់ដល់នាយកដ្ឋាននីមួយៗនូវអាជ្ញាកិច្ច ក្នុងការធ្វើទំនាក់ទំនងជាមួយក្រុមការងារបច្ចេកទេសអន្តរវិស័យ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ដូចដែលបានចែងនៅក្នុងតួនាទី និងភារកិច្ច។ ប៉ុន្តែ សម្រាប់ធានាដល់ភាពរលូននៃសកម្មភាពផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាននៃ ក.ក.ជ គេគួររៀបចំបង្កើតឡើងនូវក្រុមជំនួយការបច្ចេកទេស ហើយដែលនាយកដ្ឋាននីមួយៗ ត្រូវទទួលខុសត្រូវចូលរួមក្នុងលក្ខណៈ ២ យ៉ាង។ ក្រុមជំនួយការបច្ចេកទេស នៅ **ការិយាល័យខាងមុខ**

គួរចែកចេញជា ៤ ប្រភេទ រួមមាន**ក្រុមជំនួយការបច្ចេកទេសសម្រាប់ការកាត់បន្ថយភាពក្រីក្រ** សម្រាប់ការទទួលខុសត្រូវលើការធ្វើផែនការនិងការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សុខាភិបាល ជំនួយទ្រទ្រង់បញ្ហាជម្ងឺអេដស៍ បណ្តាញសុវត្ថិភាពសង្គម គ្រួសារឬតំបន់ដែលងាយនឹងទទួលរងគ្រោះ ការគ្រប់គ្រងនិងបែងចែកដីធ្លី... **ក្រុមជំនួយការបច្ចេកទេសសម្រាប់អាទិភាពនៃវិស័យសេដ្ឋកិច្ច** សម្រាប់ការទទួលខុសត្រូវលើវិស័យកសិកម្មនិងទឹក ការគ្រប់គ្រងដី ជលផល និងព្រៃឈើ ការអភិវឌ្ឍន៍វិស័យឯកជន ពិសេសសហគ្រាសខ្នាតតូចនិងមធ្យម... **ក្រុមជំនួយការបច្ចេកទេសអាទិភាពនៃវិស័យហេដ្ឋារចនាសម្ព័ន្ធ** រួមមាន ផ្លូវលំជនបទ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ... និង **ក្រុមជំនួយការបច្ចេកទេសសម្រាប់អភិបាលកិច្ច** រួមមាន សកម្មភាពយេនឌ័រ កំណែទម្រង់សេវាកម្មជនបទ ការធ្វើផែនការ និងការកាត់បន្ថយភាពក្រីក្រ។ នៅ **ការិយាល័យខាងក្រោយ** គេត្រូវបង្កើត**ក្រុមជំនួយការបច្ចេកទេសគ្រប់គ្រងធនធាន** រួមមាន គ្រប់ការិយាល័យក្រោមចំណុះនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងពត៌មាននិងចំណេះដឹង។ ដូច្នេះ គ្រប់ការិយាល័យចំណុះនាយកដ្ឋាន ឬគ្រប់នាយកដ្ឋានជំនាញទាំងអស់ ដែលចូលរួមក្នុងការងារខ្សែបណ្តោយទៅកាន់ក្រុមការងារបច្ចេកទេសអន្តរវិស័យផ្សេងៗគ្នា នៅស្ថាប័នខុសៗគ្នា ត្រូវចូលរួមជាក្រុមជំនួយការបច្ចេកទេសផ្ទៃក្នុងអគ្គលេខាធិការដ្ឋាននៃ ក.ក.ជ វិញ ដើម្បីផ្ទេរ ចែកចាយ និងបញ្ជូនពត៌មានទាំងនោះ ទៅកាន់នាយកដ្ឋានផ្សេងទៀត ក្នុងក្រុមជំនួយការបច្ចេកទេសរួមគ្នា។

# “គ្មានគោលដៅអ្វីសំខាន់ជាងគោលដៅនៃការ
# លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននោះទេ”

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



